Free

សារព័ត៌មាន ខ្មែរផុស្ស ស.រ.អា

# KhmerPost USA

www.khmerpostusa.com

FREE COPIES
Vol. 13. Issue #270
April 8, 2019
www.khmerpostusa.com
Office: 978-677-7163
Direct: 978-656-8141
Email: Khmerpostusa@gmail.com

## ព័ត៌មានសំខាន់ៗខាងក្នុង...

### គណបក្សសង្គ្រោះជាតិជាតិចរន្ត កឹម សុខ

*សូមអាននៅទំព័រទី ០៤*



### ប្រធានកាសែតដឺខេមបូឌាដេលី "ប៊ែណា គ្រីស្ហ័រ" ចូលមរណភាពអាយុ៨៧ឆ្នាំ

*សូមអាននៅទំព័រទី ០៥*



### បោះឆ្នោតនៅប្រទេសថៃឆ្នាំ២០១៩

*សូមអាននៅទំព័រទី ០៦*





# ត្រៀមខ្លួនចូលឆ្នាំថ្មីឆ្នាំកុរ ឯកស័ក២៥៦៣




ដោយ ពិន សំខុន

ពិធីបុណ្យចូលឆ្នាំខ្មែរ ជាពិធីដែលបានក្លាយជាទំនៀមទំលាប់តាមបែបព្រហ្មញ្ញសាសនា, តាមជំនឿពីបរមបូរាណមក គេនិយាយថា "រៀងរាល់ឆ្នាំបុត្រី៧រូបរបស់ព្រះព្រហ្ម បានដាក់វេនគ្នា នាឱកាសឆ្នាំថ្មី ដង្ហែព្រះកេស្ហ "កបិលមហាព្រហ្ម" ជុំវិញពិភព លោក ដើម្បីប្រោសព្រហ្ម ជូនពរសព្វសាធុការដល់អស់មនុស្សសត្វឱ្យប្រកបតែភាពចំរុងចំរើន"។

នៅឆ្នាំនេះ ជាឆ្នាំកុរ ឬឆ្នាំជ្រូក បុត្រីទី១ព្រះនាមនាង "ទុង្សទេវី" ជាអ្នកដង្ហែរជើងពានដែលមានព្រះកេស្ឋព្រះព្រហ្ម ហោះជុំវិញពិភពលោក នាថ្ងៃអាទិត្យ

តទៅទំព័រទី ០៩

## មេធាវី លុយហាស្កែល

Law Office of Louis S. Haskell
Serving the Cambodian Community since 1987

PERSONAL INJURY របួសរាងកាយ
AUTO ACCIDENTS គ្រោះថ្នាក់ចរាចរ





978-459-8359

16 Pine Street - Lowell, MA | www.attorneyhaskell.com

## ការិយាល័យ មេធាវី ថំមាស ស្ទាលីយ៉ាណូស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration • អន្តោប្រវេសន៍
- Auto Crash • គ្រោះថ្នាក់រថយន្ត
- Divorce • លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com

Kakrona Center Inc.
Roots Family Community

# សួស្តីឆ្នាំថ្មី ឆ្នាំកុរ








# KHMER NEW YEAR

## COMMUNITY FAIR



## SATURDAY!

## APRIL 27, 2019

RAIN DATE: May 4, 2019

## LYNN COMMONS

## 10:00 AM TO 6:00 PM



**Contact us for volunteer opportunities!**
E-mail: kakronacenter@gmail.com
Call/Text: 781-832-0999

**THANK YOU TO OUR SPONSORS!**

Element Care, Senior Whole Health, Eastern Bank, United Health Care, Rainbow Adult Day Health Center, Fallon Health-Navicare, Lynn Community Health Center, Lynn Family Dental Care, Solomine Funeral Home, Re-Max, Cinda Danh, Cambodian American Literary Arts Association, NSCC Danvers, Lynn Primary Care Center

# ការផ្លាស់ប្តូរឈ្មោះឧទ្យាននៅផ្លូវប្រែញ (Branch) ទៅជាឧទ្យានប៉ៃលិន

ដោយៈ សុប៊ិន ពិន

ឡូវែល, ម៉ាសាជូសេត "លោក រ៉ដនី អ៊ីល្បៀត អភិបាលក្រុងឡូវែល បានដាក់សំណើរនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ ២០១៩ ទៅកាន់អនុគណៈកម្មាការទីលានកំសាន្ត និងឧទ្យាន ដើម្បីសុំធ្វើការប្រជុំ និងពិភាក្សាពីការដាក់ឈ្មោះឡើងវិញនៅឧទ្យានដែលស្ថិតនៅផ្លូវប្រែញ (Branch Street) ទៅជាឧទ្យានប៉ៃលិន ។ ក្រុមប្រឹក្សានេះបានបញ្ជូនជាឯកច្ឆន្ទនូវសំណើរនៃការផ្លាស់ប្តូរនេះទៅកាន់អនុគណៈកម្មការរួចរាល់ហើយ ។

នៅឯកិច្ចប្រជុំក្រុមព្រឹក្សាសាលាក្រុងកាលពីថ្ងៃទី ១៩ ខែមិនា អនុគណៈកម្មាការទីលានកំសាន្ត និងនិងឧទ្យាន បានជួបជុំគ្នា និងសម្រេចគាំទ្រចំពោះការប្តូរឈ្មោះសួនឧទ្យាននេះ ។ ក្រុមព្រឹក្សាក្រុងបានយ៉ោងសំណើររបស់លោក អ៊ីល្បៀត ទៅកាន់ក្រុមប្រឹក្សាឧទ្យាន ហើយការបោះឆ្នោតចុងបញ្ចប់ នឹងត្រូវធ្វើឡើងនៅកំឡុងពេលខែមេសានេះ ។ ជាមួយនឹងការប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីខ្មែរជារៀងរាល់ឆ្នាំដែលប្រព្រឹត្តទៅនៅឯសួនឧទ្យាននេះសម្រាប់ថ្ងៃទី២០ខែមេសាឆ្នាំនេះសហគមន៍ខ្មែរក្រុងឡូវែល អាចនឹងមានឱកាសក្នុងការរៀបចំចូលឆ្នាំថ្មីជាមួយនឹងមោទនភាពថ្មីដែលមានឧទ្យានត្រូវបានគេដាក់ឈ្មោះជាថ្មី នៅទីតាំងបណ្តុំទៅដោយវប្បធម៌ ដែល



KP USA File Photo: Cambodian traditional game "Tugs of War" was being played at the Clemente Park during a Cambodian New Year celebration in April 2016.



KP USA Photo: Pailin Plaza on Middlesex Street across from the Clemente Park

គ្រាន់តែឆ្លងផ្លូវម្ខាងដែលមានឈ្មោះថា ប៉ៃលិន ផ្លាសា ដែលត្រូវបានបង្កើតឡើងនៅក្នុងទសវត្សរ៍ឆ្នាំ ១៩៥០ ។

ឧទ្យានរ៉ូប៉េតូ ក្លេម៉ិនតេផាក ធ្លាប់ជាទីលានបាល់ប៉ះដែលសហគមន៍អាមេរិកឡាទីនធ្លាប់ប្រមូលផ្តុំគ្នានៅក្នុងទសវត្សរ៍ឆ្នាំ ១៩៧០ មុននឹងការមកដល់របស់ជនភាសខ្លួនខ្មែរ ។ កាលពីមុនឧទ្យាននេះ ត្រូវបានគេហៅថា ឧទ្យានវ៉ាស៊ីនតោន ហើយបន្ទាប់មកត្រូវបានផ្លាស់ប្តូរទៅជាឧទ្យានរ៉ូប៉េតូ ក្លេម៉ិនតេផាក នៅក្នុងទសវត្សរ៍ឆ្នាំ១៩៧៣ ដើម្បីជាការផ្តល់ជាកិត្តិយសដល់កីឡាករបាល់បោះអាជីពដែលមានដើមកំណើតព័រតូរីកូដែលបានស្លាប់ដោយការធ្លាក់យន្តហោះមួយក្នុងអំឡុងពេលធ្វើដំណើរមនុស្សធម៌ទៅកាន់អាមេរិកឡាទីននោះ ។

លោក អ៊ីល្បៀត បានមានប្រសាសន៍ថា "ពេលបានផ្លាស់ប្តូរផ្នែកជាច្រើននៅក្រុងឡូវែល ។ កាលពី ៣០ ឆ្នាំមុន ក្លេម៉ិនតេផាកគឺជាទីកន្លែងប្រមូលផ្តុំសម្រាប់សហគមន៍ខ្មែរដើម្បីលេងកីឡា, ប្រារព្ធពិធីសាសនា, ទីកន្លែងលេងរបស់ក្មេងៗ និងគ្រួសារ ។ ឧទ្យាននេះ ផ្តល់ដល់សហគន៏នូវមោទនភាពយ៉ាងក្រៃលែងតាមរយៈការផ្លាស់ប្តូរឈ្មោះថ្មីទៅជាឧទ្យានប៉ៃលិន" ។

ការស្នើរផ្លាស់ប្តូរឈ្មោះ គឺត្រូវបានធ្វើឡើងតាំងពីឆ្នាំមុនមកម្លេះតាមរយៈលោក អ៊ីល្បៀត ដែលជាសមាជិកក្រុមប្រឹក្សាក្រុងរួមជាមួយលោកក្រុមប្រឹក្សាក្រុង វ៉ាស្នា នួន ប៉ុន្តែត្រូវបានសមាជិកក្រុមប្រឹក្សាក្រុងលោក រីតា មេស័រ ធ្វើការជំទាស់ចំពោះសំណើរនេះ ដោយសារតែវាក៏ធ្វើឱ្យប៉ះពាល់មោទនភាពរបស់សហគមន៏អាមេរិកឡាទីនដែលជាឈ្មោះរបស់កីឡាករបាល់បោះគំរូរបស់ពួកគេ ។ ទោះបីជាយ៉ាងណាក៏ដោយ លោក អ៊ីល្បៀត បានជំទាស់ដោយបានលើកឡើងថា សហគមន៏អាមេរិកឡាទីន លែងប្រើ

តទៅទំព័រទី ២១



មណ្ឌលពិនិត្យសុខភាពឡូវ៉ែល

Lowell Primary Care Center

លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.

Sokharith Mey, M.D. Chhan Touch, C.N.P.

ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

Now Accepting New Patients

ជំងឺទូទៅ សុខភាពផ្លូវចិត្ត

Family Medicine & Behavioral Health



អាស័យដ្ឋាន

1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992

ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត

បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances

Our Staff Speaks Khmer • Plenty of Free Parking

# គណបក្សសង្គ្រោះជាតិចរន្ត កឹម សុខា

ដោយ ពិន សំខុន

គេតែងតែឮពាក្យថា"គណបក្សសង្គ្រោះជាតិចរន្ត សម រង្ស៊ី" ឬ "គណបក្សសង្គ្រោះជាតិចរន្ត កឹម សុខា"តើចរន្តទាំងនោះជាអ្វី?

គណកម្មការសង្គ្រោះជាតិ USA គឺជាចរន្តដឹកនាំដោយដំណាងរាស្ត្រញ៉ែមប៊ុញ្ញាប្ញទ្ធ-ង៉ោ គឹមឈៀង-ពិន រតនា-ទូន យក់ដា-ហ៊ីង សុខសាន្ត នឹងមន្ត្រីជាន់ខ្ពស់កញ្ញា កឹម មនោវិទ្យា- មាច សុវណ្ណារ៉ា (នៅពេលលោក កឹម សុខា ជាប់ការឃុំឃាំងនៅកម្ពុជា) បានបើកកិច្ចប្រជុំសន្និបាទបិទទ្វារមួយរយៈពេល ១៣ម៉ោង កាលពីថ្ងៃសៅរ៍ ទី៣០មិនា២០១៩ នៅវត្តសុរិយារង្សី (ហៅវត្តកម្ពុជាក្រោម) រដ្ឋហ្វីឡាដែលហ្វៀ ដោយមានដំណាង៦០នាក់មកពីរដ្ឋជាច្រើននៃសហរដ្ឋអាមេរិក-បារាំងនឹងកាណាដា ក្រោមការប្រោះព្រហ្មជយន្តោ ពីព្រះសង្ឃទៀតផង។

នៅពេលដែលលោក សម រង្ស៊ី កំពុងស្វែងរកច្រកចូលកម្ពុជា ហើយវែកផ្លូវតាមរយៈរចនាសម្ព័ន្ធនយោបាយមួយលោកបានប្រទះ (កាលពីថ្ងៃ ២ធ្នូ ២០១៨ នៅអាត់ឡង់តា) គឺគណបក្សចាស់របស់លោក ដែលលោកមិនចង់ប្រើវាពីមុនមកទេ គឺគណបក្សសង្គ្រោះជាតិ ដែលបានត្រូវលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន រំលាយទៅហើយនោះ។ តាមពិតទៅ នៅក្នុងគណបក្សសង្គ្រោះជាតិក្រៅប្រទេសមានចរន្តគណបក្សសង្គ្រោះជាតិ២ក្រុម ១-គឺគណបក្សសង្គ្រោះជាតិអាមេរិកខាងជើង ហៅថា"ចរន្តលោក សម រង្ស៊ី-North America NA"ដឹកនាំដោយលោក ជា គឹមលី - អ៊ុង វិទ្ធី ២-មួយក្រុមទៀត ដែលគេមិនសូវនិយាយគឺក្រុមដែលគិតថា"ខ្លួនគេមិនអាចត្រូវរំលាយដោយលោក ហ៊ុន សែន បាននោះបាននៅឡើយទេ"គឺចរន្តសង្គ្រោះជាតិ" សហរដ្ឋអាមេរិក-USA" ដឹកនាំនៅឡូវែល ដោយលោក ស៊ីនួន ខាំ នឹង តាំន់ ប៉េងអាន ឬខ្លះគេហៅថា"គណបក្សសង្គ្រោះជាតិចរន្ត កឹម សុខា" ដែលក្រុមខាងក្រោយនេះ គេនៅគាំទ្រសកម្មភាព នាង កឹម មនោវិទ្យា ជានាយករងកិច្ចការបរទេស នឹងលោក ញ៉ែម ប៉ុញ្ញារិទ្ធ អគ្គលេខារបស់គណបក្សសង្គ្រោះជាតិ ដែលជាចរន្តលោក កឹម សុខា នៅជាប់ឃុំឃាំងនៅឡើយ ។

តើមានអ្វីកើតឡើង បានជានៅពេលដ៏លំបាកគណបក្សសង្គ្រោះជាតិបែរជាមិននៅរួមកម្លាំងជាមួយគ្នាយ៉ាងនេះ?

ឆ្នាំ២០១២ ជាឆ្នាំដែលគណបក្សសង្គ្រោះជាតិបានត្រូវបង្កើតឡើង ។ អ្នកគាំទ្រពីក្រៅប្រទេស គឺទាំងអស់គ្នាជាក្រុមអ្នក"គាំទ្រ"មិនមែនជា"សមាជិកគណបក្ស"ឡេ ហើយចែកគ្នាជា២ក្រុមរួចទៅហើយ តែក្រុមលោក សម រង្ស៊ី មានអាយុចាស់ជាង។ គណបក្ស សម រង្ស៊ី ថ្វីត្បិតតែនៅពេលដែលច្របាច់បញ្ចូលគ្នាជាមួយគណបក្សសិទ្ធិមនុស្ស ឱ្យកើតជា"ក្រុមអ្នកគាំទ្រគណបក្សសង្គ្រោះជាតិUSA"ជាផ្លូវការហើយក៏ដោយ ក៏លោក សម រង្ស៊ី នៅតែរក្សារចនាសម្ព័ន្ធចរន្តក្រៅប្រទេសរបស់លោក គឺសង្គ្រោះ ជាតិ "ណា" មិនឱ្យរលាយបាត់ទៅណាជារហូតមក។ នៅពេលដែលលោក សម រង្ស៊ី បានលាលែងពីដំណែងប្រធានភ្លាមដែលលោកថា"ដើម្បីទប់ទល់ការប៉ុនប៉ងរំលាយគណបក្សសង្គ្រោះជាតិ" គឺក្រុមគាំទ្រចរន្ត"សង្គ្រោះ



លោក ញ៉ែម បុញ្ញារិទ្ធ អតីតតំណាងរាស្ត្រខ្មែរ



កញ្ញា កឹម មនោវិទ្យា អគ្គនាយករង កិច្ចការបរទេសរបស់គណបក្សសង្គ្រោះជាតិ

ជាតិNA"ដែលជាកម្លាំងដ៏ស្មោះស្ម័ក្ររបស់ សម រង្ស៊ី ហើយមើលស្រាលទៅលើ"សង្គ្រោះជាតិ USA"ដោយពេលនោះគិតថា លោក កឹម សុខា ជាប់គុកបាត់ទៅហើយ ធ្វើនយោបាយជាមួយ "គណបក្សសង្គ្រោះជាតិ"ក៏រលាយបាត់ទៅហើយដែរ ដូច្នេះលោកត្រូវរកមធ្យោបាយចេញមុខ ជម្រុញឱ្យមាន "ការចរចាជាមួយនឹងរបប ហ៊ុន សែន"ឡើងវិញ។ លោក សម រង្ស៊ី (ពេលនោះដឹងខ្លួនថា: ជាទណ្ឌិតមិនអាចនៅជាថ្នាក់ដឹកនាំគណបក្សណាមួយបានទេ) ជាមួយនឹង



ជួបប្រជុំក្រុមគាំទ្រគណបក្សសង្គ្រោះជាតិសហរដ្ឋអាមេរិក ចរន្ត កឹម សុខា នៅហ្វីឡាដែលហ្វៀ

សង្គ្រោះជាតិ NA របស់លោក បានបង្កើតជាសមាគមប្រជាធិបតេយ្យមួយ បន្ទាប់មកបង្កើតបានជាចលនាសង្គ្រោះជាតិមួយជាពីរជាបីទៀត ដើម្បីឱ្យមានឈ្មោះមួយសម្រាប់ឱ្យអន្តរជាតិទទួលស្គាល់... តែមិនបានជោគជ័យសោះ ពីព្រោះសហគមន៍អន្តរជាតិ គេមិនបានថា"គណបក្សសង្គ្រោះជាតិ"បានស្លាប់ដូចបណ្ដាសារលោក ហ៊ុន សែន នោះឡើយ។ ចុងបញ្ចប់លោក សម រង្ស៊ី ក៏ត្រឡប់មកយកតំណែងជាប្រធានស្តីទីលើកបន្ទុបដោយក្រុមគណអចិន្ត្រៃយ៍គណបក្ស ដែលជាមនុស្សជំនិតជាអតីតសមាជិកសភារបស់លោក នឹងមានជំនួយពីក្រុម NA យ៉ាងពេញទំហឹងផង។

រីឯចរន្តក្រៅប្រទេសដែលនៅសល់គឺ"សង្គ្រោះជាតិUSA" បន្តរធ្វើដំណើរទន្ទឹមគ្នានឹងក្រុម NA រហូតដល់មានការប៉ុនប៉ងរំលាយក្រុមសង្គ្រោះជាតិ USA ដោយការកាត់យកតែក្បាល9គឺយកតែមេកើយ).. ពេលនោះ ក្រុម USA(ឥតក្បាល) គេនៅគាំទ្រការតស៊ូជាមួយសហគមន៍អន្តរជាតិ ហើយបន្តរទទួលស្គាល់ថា"គណបក្សសង្គ្រោះជាតិ"មិនបានត្រូវរលាយដោយដៃ ហ៊ុន សែន នោះទេ គឺជាក្រុមដែលមិនបានឆ្លេឆ្លារត់តាមលោក សម រង្ស៊ី ហើយបានក្លាយជាក្រុមលោក កឹម សុខា ដោយសារតែការនៅសេសសល់នឹងដោយការសន្មត់ ជាពិសេសគឺជាក្រុមមិនបានចាកចេញពីគោលការដើម នៅតែគាំទ្រសកម្មភាព នាង កឹម មនោវិទ្យា ជាកូនស្រីលោក កឹម សុខា នឹងលោក ញ៉ែម ប៉ុញ្ញារឹទ្ធ ដែលនៅតែបន្តរមានទំនាក់ទំនងជាប់កិត ជាមួយនឹងសហគមន៍អន្តរជាតិដាក់សម្ពាតឱ្យលោក ហ៊ុន សែន ហើយក៏ប្តើមទាមទារឱ្យមានការដោះលែងលោក កឹម សុខា ប្រធានគណបក្សប្រឆាំងចេញពីពន្ធនាគារ ដែលបានក្លាយទៅជាជំហ៊ារ នឹងលក្ខខណ្ឌដំបូងបង្អស់នឹងសំខាន់បំផុត របស់សហគមន៍អន្តរជាតិ មានអឺរ៉ុប នឹង សហរដ្ឋអាមេរិកផង។,

ឃើញមានការខូចខាតដោយអន្លើ ចំពោះអង្គការគាំទ្រសង្គ្រោះជាតិផ្លូវការ, កាលថ្ងៃទី១០ មិនា មានកិច្ចប្រជុំមួយ នៅឡូវែល ក្រោមអធិបតីភាពនៃលោក យ៉ែម ប៉ុញ្ញាប្ញទ្ធិ នឹងលោក ង៉ោ គឹមឈាង ទាំងពីររូបជាតំណាងរាស្ត្រនៃគណបក្សសង្គ្រោះជាតិជាមួយនឹង"អ្នកគាំទ្រសង្គ្រោះជាតិ USA នៅឡូវែល" មានសមាជិកដំណាងជាង៣០នាក់ចូលរួមប្រជុំដឹកនាំដោយលោក ស៊ីនួន ខាំ នឹង លោក ប៉េង អាន, ដើម្បីរៀបចំជួសជុលរចនាសម្ព័ន្ធឡើងវិញ បន្ទាប់ពីការចាកចេញរបស់សមាជិកមួយចំនួន ទៅកាន់ក្រុមលោក សមរង្ស៊ី ។ ពីកិច្ចប្រជុំនោះ គេបានដឹងថា: "គេទទួលស្គាល់ថា មានការប្រេះឆាក្នុងរង្វង់គណបក្សសង្គ្រោះជាតិមែន ដោយសារការស្វែងរកដំណោះស្រាយនយោបាយក្នុងប្រទេសមិនដូចគ្នា, -លោក កឹម សុខា បានទទួលដំណឹងទាំងអម្បាមាណយ៉ាងគ្រប់គ្រាន់ ហើយហាមឃាត់មិនឱ្យឆ្លើយតបនឹងការចោទប្រកាន់ឥតប្រយោជន៍មិនថ្លៃថ្នូ, ក្រុមសង្គ្រោះជាតិប្រទេសបារាំងរួមជាមួយដំណាងរាស្ត្រខ្មែរស្នាក់នៅទីនោះ បានរួមប្រជុំ ហើយរង់ចាំសេចក្ដីសម្រេចរួមពីសហរដ្ឋអាមេរិក, នឹងមានកិច្ចប្រជុំរបស់ក្រុម USA ទាំងមូលនាចុងខែមិនានៅហ្វីឡាដែលហ្វៀដើម្បីបញ្ចេញសេចក្ដីថ្លែងការរួមមួយពីសហរដ្ឋអាមេរិក បញ្ជូនតបទៅសំណើរខាងប្រទេសបារាំងវិញ, សម្រាប់ចុងបញ្ចប់រៀបចំកិច្ចប្រជុំពិភពលោកមួយ,".... គេអាចសង្កេតឃើញថា ក្រុមចុងក្រោយនេះ មានការប្រុងប្រយ័ត្នមិនធ្វើអ្វីដែលនាំឱ្យរឹតតែមានការប្រេះឆាផ្ទៃក្នុងរឹតតែខ្លាំងនោះទេ ហើយក៏មិនចង់បន្ថែមទម្ងន់អ្វីឱ្យលោកប្រធានរបស់គេ រឹតតែជាប់ទោសកាន់តែធ្ងន់ កាន់តែយូរនោះឡើយដែរ, ប៉ុន្តែបើទោះជាក្រុម USA មានគោលដៅដូចគ្នានឹងណាក៏ដោយ គឺប្រឆាំងនឹងអំណាចផ្តាច់ការនៃរបប ហ៊ុន សែន ក្តី ក៏មិនអនុញ្ញាត្តិឱ្យលោក សម រង្ស៊ី ជិះសេះលែងដៃទៅ"ប្តូរគោលដៅតស៊ូមតិនយោបាយ"នៅប្រទេសកម្ពុជានោះដែរ ។

នៅពេលដែលលោក កឹម សុខា នៅក្នុងការឃុំឃាំងនៅឡើយ លោក ហ៊ុន សែន មុខតែនឹងបានរីករាយ ដោយឃើញសង្គ្រោះជាតិជាសត្រូវបានបែកគ្នាជា២ជម្រោកជាមិនខាន ។ ប៉ុន្តែចាប់ពីដើមខែមេសានេះទៅ ក្រុមUSA បានសម្រេចចិត្ត"ពង្រឹងជំហ៊ររបស់ខ្លួនឡើងវិញ-សន្យាឆ្លើតតបនឹងការផ្សព្វផ្សាយព័តិមានមិនពិតជូនសាធារណជន តែមិនតបតនឹងការវ៉ាយប្រហាររបស់ក្រុម គាំទ្រលោក សម រង្ស៊ី ទេ- គេនៅបន្តធ្វើការជាមួយសហគមន៍អន្តរជាតិ មាន EU – USA – Australy – Japon – Canada... ដាក់សម្ពាធលើរដ្ឋាភិបាលភ្នំពេញ រហូតដល់មានការដោះលែងលោក កឹម សុខា ជាស្ពាពរនឹង"ធ្វើឱ្យកម្ពុជាត្រឡប់មករកយន្តការប្រជាធិបតេយ្យដូចមុនឡើងវិញ "- ហើយមិនធ្វើអត្ថាធិប្បាយអ្វី ចំពោះអ្នកនយោបាយខ្មែរដែលបានសុំសិទ្ធិចូលទៅធ្វើនយោបាយវិញពេលនេះទេ" ។

ក្រុមបដិសណ្ឋារកិច្ចហ្វីឡាដែលហ្វៀជាម្ចាស់ផ្ទះមានលោក វ៉ា សាម៉ុន- មាស ជា - អ៊ុន តាំងហ្វូ ព្រមទាំងភរិយារួមទាំងអ្នកឯទៀត បានផ្តល់ការទទួលភ្ញៀវយ៉ាងកក់ក្តៅ តាំងពីកន្លែងប្រជុំ ទទួលភោជនាហារឈ្ងុយឆ្ងាញ់នឹងបរិបូណ៍ កន្លែងស្នាក់អាស្រ័យនឹងការទស្សនាទីក្រុង ក្នុងរយពេល២ថ្ងៃយ៉ាងភាតរភាពជាគំរូនឹងគួរឱ្យចងចាំជាទីបំផុត ។

# ប្រធានកាសែតដីខេមបូឌាដេលី "ប៊ែណា គ្រីស្ស័រ" ចូលមរណភាពក្នុងអាយុ៨៧ឆ្នាំ

ដោយ ពិន សំខុន

មិត្តរបស់កម្ពុជាម្នាក់នឹងជាមិត្តរបស់ខ្លួនខ្ញុំម្នាក់ដែរ ជាអ្នកជួយខ្នះខ្នែងកសាងប្រទេសដែលមិនមែនជាប្រទេសរបស់ខ្លួនគាត់ បានបាត់បង់ជីវិតយ៉ាងគួរឱ្យសោកស្តាយ កាលពិថ្ងៃទី៥មិនា ២០១៩ ក្នុងជន្មាយុ៨៧ឆ្នាំ នៅទីក្រុងតូក្យូ ដែលជាផ្ទះរបស់គាត់ ដោយជម្ងឺបេះដូង។ លោកឈ្មោះ"ប៊ែណា គ្រីស័រ-Bernard Krisher"ជាម្ចាស់នៃកាសែត"ដឹខាមបូឌាដេលី-The Cambodia Daily"ដំណើរការពីឆ្នាំ១៩៩៣-២០១៧។ លោកក៏ជាអ្នកផ្តត់ផ្គង់ថវិការដល់មន្ទីពេទ្យធំ៧៣កន្លែង ឱ្យពលរដ្ឋក្រីក្រអាចព្យាបាលបាន ដោយមិនយកកំរៃ គឺ"ពេទ្យក្តីសង្ឃឹម"នៅភ្នំពេញ"ពេទ្យគន្ធបុប្ផា"នៅភ្នំពេញ នឹង"ពេទ្យកុមារ"នៅសៀមរាប, ជាអ្នកសង់សាលរៀននៅពាសពេញកម្ពុជាចំនួនជាង៥០០ខ្នង, ហើយជាអ្នកដែលបានបង្កើតបានសាលាវិជ្ជាជីវៈសារព័តិមាននៅសាកលវិទ្យាល័យភ្នំពេញ ដំណើរការពីឆ្នាំ១៩៩៦-សព្វថ្ងៃ។

ប៊ែណា គ្រីស័រ ក៏ជាមិត្តដ៏ជិតស្និតម្នាក់របស់សម្តេចនរោត្តម សីហនុ ដែរ, ពេលស្លាប់ទៅហើយក្តី លោកបានបន្សល់ទុកនូវស្នាដៃឆ្នើមបំផុត គឺកាសែត"ដឹខាបូឌាដេលី"ខ្នាតតូចមែន តែមានគុណភាពគំរូនៃ



លោក ប៊ែល ណាគ្រីស័រ ជាអ្នកសារព័តិមានដ៏ឆ្នើម ជាប្រធានកាសែតកាមបូឌាដេលី



លោក ប៊ែល ណាគ្រីស័រ ជាមិត្តជិតស្និតរបស់សម្តេច សីហនុ

សេរីភាពសារព័តិមាន-នៃវិជ្ជាជីវៈជាអ្នកសារព័តិមាន-នៃសីលធមិដែលអ្នកសារព័តិមានតែងគោរពមិនឱ្យឃ្លាត... ផ្តល់ព័តិមានពិត។ ដល់ពលរដ្ឋជារៀងរាល់ថ្ងៃ... លោកក៏បានទុកឱ្យកម្ពុជានូវ"វិជ្ជាស្ថានសារព័តិមាន"នៅមហាវិទ្យាលិយភ្នំពេញ ដែលបន្តបណ្តុះបណ្តាលសេរីភាពសារព័តិមានដល់យុវជនដំណើរការរហូតដល់សព្វថ្ងៃ។ ជាមនុស្សនិយាយតិចតួច តែធ្វើការជូនកម្ពុជាយ៉ាងអំណត់ គិតដល់ជំរៅនៃអនាគតរបស់ជនជាតិ ដែលទើបនឹងងើបចេញពីឋាននរកកុម្មុយនិស្តគឺសង់សាលាជូនកូនខ្មែររាប់រយខ្នងសង់មន្ទីរពេទ្យជូនអ្នកដែលគ្មានលុយបង់ថ្លៃព្យាបាលជម្ងឺ... ប៉ុន្តែរដ្ឋាភិបាលសព្វថ្ងៃ មិនបានទទួលស្គាល់គុណសម្បត្តិរបស់ ប៊ែណា គ្រីស្ស័រ ថាជាសម្បត្តិរបស់ជាតិ នឹងពលរដ្ឋខ្មែរនោះទេ ពីព្រោះគេបានបិទកាសែតដ៏មានតម្លៃនោះចោលកាលពីឆ្នាំ២០១៧ ទៅហើយ ។

ប៊ែណា គ្រីស្ស័រ មិនមែនជាអ្នកមានលុយវាលលានទេ តែលោកគ្រួសារជាតិជីវ ធ្លាប់ជាអ្នកសារព័តិមានច្រើនឆ្នាំនៅញូយ៉ក បន្ទាប់ពីលោកជន្លាសខ្លួនពីប្រទេសអាល្លឺម៉ង់មក, លោកមានភរិយាជាតិជប៉ុនមានកូន២នាក់ ។ បន្ទាប់ពិបានជួបសម្តេចនរោត្តម ស៊ីហនុ នៅពេលមានកិច្ចព្រមព្រៀងក្រុងប៉ារីសឆ្នាំ១៩៩១មក លោកបានដានទទួលការណែនាំ ហើយផ្តើមយកចិត្តនឹងជីវិតមកទុកដាក់នៅឯប្រទេសកម្ពុជាតាំងតែពីពេលនោះមក ។

ខ្ញុំបានជួបពិភក្សាគ្នាជាញយដងជាមួយ"ប៊ែណា"នៅភ្នំពេញ ដែលគាត់ចូលចិត្តឱ្យបណ្តាមិត្តរបស់គាត់ហៅថា"ប៊ែនី"វិញ លោកជាមនុស្សសាច់ការមិនសូវមានពេលទំនេរទេ តទៅទំព័រទី ០៦


## WANT TO DRIVE FOR THE LRTA?




# NOW HIRING

## Full-Time & Part-Time Bus Drivers

CDL-A or CDL-B with Passenger Endorsement required

Other LRTA requirements may apply

**Monday - Sunday**

5 Day Work Week • Some Split Shifts

***Full-Time Bus Drivers Receive:***

*Competitive Pay Rate • Medical & Life Insurance • 401K • And More!*

**Apply In Person**

**Lowell Regional Transit Authority**

100 Hale Street • Lowell, MA • Mon-Fri: 8 am - 4 pm

**For More Info**

**Call 978-452-6161**

Lowell Regional Transit Authority

An Equal Opportunity Employer

**www.LRTA.com**

# បោះឆ្នោតនៅប្រទេសថៃឆ្នាំ២០១៩

ដោយ ពិន សំខុន

ប្រទេសជិតខាងខ្មែរមួយ គឺប្រទេសថៃ ទើបនឹងធ្វើការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ កាលពីថ្ងៃទី២៤មិនា២០១៩កន្លងទៅ បន្ទាប់ពីមានរដ្ឋប្រហារ



គណបក្ស ប៉ាឡាំង ប៉ាឆារ៉ាត់ ចរន្ត លោក ប្រាយុទ្ធ ចាន់អូចារ

យោធា កាលពីឆ្នាំ២០១៤ រំលាយសភាចោល ហើយពីរដ្ឋប្រហារនោះ ឧត្តមសេនីយ ប្រាយុទ្ធ ចាន់អូចារ បានឡើងកាន់ដំណែងជានាយករដ្ឋមន្ត្រីតាំងពីពេលនោះមក ដោយគ្មានឱ្យមានការបោះឆ្នោតអ្វីទៀតរហូតទល់ពេលនេះ។

គណបក្សចំនួន៧៧បានចូលរួមប្រកួត យកដំណែងសភាដំណាងរាស្ត្រចំនួន៥០០អាសនៈ តាមរូបមន្តនៃធម្មនុញ្ញថ្មី សរសេរនឹងអនុម័តដោយអំណាចក្រុមយោធាថៃ កាលពីឆ្នាំ២០១៧ ។ អ្នកសង្កេតការមិនបានវាយតម្លៃថា រដ្ឋធម្មនុញ្ញនោះនឹងផ្តល់ភាពយុត្តិធម៌គ្រប់គ្រាន់ដល់គណបក្សផ្សេងពីក្រុមយោធានោះទេ។ ទោះជាយ៉ាងនេះក៏ដោយក្តី គណបក្ស"ប៉ាឡាំង ប៉ាឆារ៉ាត"ដឹកនាំដោយលោក ប្រាយុទ្ធ ចាន់អូចារ បានសន្លឹកឆ្នោតច្រើនជាងគេមែន បែរជាបានអាសនៈតែ១១៦ តិចជាង""គណបក្សភឿថៃ""គាំទ្រដោយលោក ថាក់ស៊ីន ស៊ីណាវ៉ាត្រា ដែលទទួលបាន១៣៦អាសនៈជាចំនួនអាសនៈច្រើនជាងគេ។ គណបក្សដែលបានចំណាត់ថ្នាក់បន្ទាប់ គឺគណបក្ស"ឆ្ពោះទៅអនាគត",គណបក្ស"ប្រជាធិបតេយ្យ",គណបក្ស"ភូមថៃថៃ"...។

ការតែងតាំងនាយករដ្ឋមន្ត្រី មិនអាស្រ័យទៅលើគណបក្សដែលទទួលបានអាសនៈច្រើន ឬតិចនោះទេ ធម្មនុញ្ញថ្មីនិយាយថា"គឺសភាដំណាងរាស្ត្រ៥០០នាក់ នឹងព្រឹទ្ធសភា២៥០នាក់ ជាអ្នកសម្តែងការទុកចិត្តលើនាយករដ្ឋមន្ត្រី ដែលមិនចាំបាច់តែជាអ្នកជាប់ឆ្នោតក៏បានដែរឱ្យតែមានលក្ខណៈសម្បត្តិគ្រប់គ្រាន់..."។ គួររំលឹកថា អាសនៈ២៥០របស់ព្រឹទ្ធសភាយោងតាមធម្មនុញ្ញថ្មី គឺក្រុមយោធាជាអ្នកតែងតាំងទាំងអស់, បន្ថែមពីនោះទៀត គេដឹងថា"ដើម្បីឱ្យបាន



គណបក្ស ភឿ ថៃ ចរន្តលោក ថាក់ស៊ីន ស៊ីវ៉ាត្រា

សម្លេងភាគច្រើននៅសភាដំណាងរាស្ត្រ ក្រុមយោធាបានទៅចងសម្ព័ន្ធភាពជាមួយគណបក្សតូចៗបន្ទាប់មានគណបក្សប្រជាធិបតេយ្យ -គណបក្ស"ឆ្ពោះទៅអនាគត"ដែលសម្បូរទៅដោយក្រុមយុវជនថៃជាអ្នកចូលរួម...។

ការបោះឆ្នោតលើកក្រោយបង្អស់នេះ បានទទួលការទិទានជាច្រើន ពីសំណាក់ក្រុមសិទ្ធិមនុស្សនឹងក្រុមអ្នកសង្កេតការ ដោយសារមាន់ភាពមិនប្រក្រដី នឹងកំហុសជាច្រើនអន្លើរបស់គណកម្មការបោះឆ្នោត, ហើយគណកម្មការនោះទៀតសោត បានលើកការប្រកាសលទ្ធផលជាច្រើនដង លទ្ធផលដែលគ្រោងថានឹងចេញនៅថ្ងៃទី២៨មិនា បានត្រូវលើកជាបន្តបន្ទាប់...ឥឡូវនេះបាន សន្យាថានឹងបានចប់ជាស្ថាពរនៅថ្ងៃទី៩ ខែឧសភាវិញ។ លទ្ធផលបណ្តោះអាសន្នៃនចំនួនសន្លឹកឆ្នោត នឹង ចំនួនអាសនៈដែលគណបក្សទាំងអស់ទទួលបានគឺៈ

ពីអតីតកាល ប្រទេសថៃស្ថិតនៅក្នុងចំណាត់ថ្នាក់នៃប្រទេសប្រជាធិបតេយ្យក៏រឹតខ្ពស់មួយ តែបន្ទាប់ពីរដ្ឋប្រហារមក ក៏ក្លាយទៅប្រទេសផ្តាច់ការដូចប្រទេសកុម្មុយនិស្តដែរ។ តើបន្ទាប់ពីការបោះឆ្នោតនេះរួចទៅ តើប្រទេសថៃនឹងត្រឡប់មករកលទ្ធិប្រជាធិបតេយ្យវិញដែរឬទេ? តើនាយករដ្ឋមន្ត្រីថៃថ្មីមុខ ជាសមាជិកគណបក្សណាមួយ ដែលនឹងដឹកនាំប្រទេសថៃទៅអនាគត? សូមតាមដាន អនាគតនយោបាយប្រទេសថៃនៅលេខក្រោយទៀត។





| Party | Popular votes: Votes | % | Seats: Constituency | Party list | Total |
|---|---|---|---|---|---|
| Pheu Thai Party | 7,920,630 | 22.29 | 137 | 0 | 137 |
| Palang Pracharath Party | 8,433,137 | 23.73 | 97 | 19 | 116 |
| Future Forward Party | 6,265,950 | 17.63 | 30 | 50 | 80 |
| Democrat Party | 3,947,726 | 11.11 | 33 | 19 | 52 |
| Bhumjaithai Party | 3,732,883 | 10.51 | 39 | 12 | 51 |
| Thai Liberal Party | 826,530 | 2.33 | 0 | 10 | 10 |
| Chartthaipattana Party | 782,031 | 2.20 | 6 | 4 | 10 |
| Prachachart Party | 485,436 | 1.37 | 6 | 1 | 7 |
| New Economics Party | 485,664 | 1.37 | 0 | 6 | 6 |
| Puea Chat Party | 419,393 | 1.18 | 0 | 5 | 5 |
| Action Coalition for Thailand | 416,324 | 1.17 | 1 | 4 | 5 |
| Chart Pattana Party | 252,044 | 0.71 | 1 | 2 | 3 |
| Thai Local Power Party | 213,129 | 0.59 | 0 | 3 | 3 |
| Thai Forest Conservation Party | 136,597 | 0.39 | 0 | 2 | 2 |
| Thai People Power Party | 81,733 | 0.23 | 0 | 1 | 1 |
| Thai Nation Power Party | 73,871 | 0.21 | 0 | 1 | 1 |
| People Progressive Party | 69,417 | 0.19 | 0 | 1 | 1 |
| Palang Thai Rak Thai Party | 60,840 | 0.17 | 0 | 1 | 1 |
| Thai Civilized Party | 60,421 | 0.17 | 0 | 1 | 1 |
| Prachaniyom Party | 56,617 | 0.16 | 0 | 1 | 1 |
| Thai Teachers for People Party | 56,339 | 0.16 | 0 | 1 | 1 |
| Thai People Justice Party | 47,848 | 0.13 | 0 | 1 | 1 |
| People Reform Party | 45,508 | 0.13 | 0 | 1 | 1 |
| Thai Citizens Power Party | 44,766 | 0.12 | 0 | 1 | 1 |
| New Democracy Party | 39,792 | 0.11 | 0 | 1 | 1 |
| New Palangdharma Party | 35,533 | 0.10 | 0 | 1 | 1 |
| Thairaktham Party | 33,748 | 0.09 | 0 | 1 | 1 |
| Puea Pandin Party | 31,307 | 0.17 | 0 | 0 | 0 |
| **Total** | **35,532,647** | **100** | **350** | **150** | **500** |
| Invalid/blank votes | 2,130,327 | 5.57 | | | |
| None of the above | 605,392 | 1.58 | | | |
| **Votes cast/turnout** | **38,268,366** | **74.69** | | | |
| Abstentions | 12,971,272 | 25.31 | | | |
| Registered voters | 51,239,638 | | | | |

Sources: Election Commission (votes, constituency)

តមកពីទំព័រទី ០៥

## ប្រធានកាសែតដឹកាមបូឌាដេលី...

ហើយក៏មិនមែនជាអ្នកស៊ីផឹកទៀតផង។ ការងារកាសែតជាជំនាញនឹងជាចំណូលចិត្តរបស់គាត់នឹងដែលធ្វើឱ្យមនុស្សម្នា ធំតូច ម ន្ត្រី ឬរាស្ត្រធម្មតា នៅកម្ពុជាទាំងអស់ស្គាល់នឹងគោរពជាមនុស្សអស្ចារ្យគ្រប់ៗគ្នា។ នៅពេលបង្កើត"វិជ្ជាស្ថានសារព័ត៌មាន" ចំពេលដែលមានទំនាស់រវាងសមាគម២ ដែលម្ខាងជាសមាគមឯករាជ្យ ដែលមានខ្លួនខ្ញុំ(ពិន សំខុន)ជាប្រធានម្ខាងទៀតមានសម្ព័ន្ធអ្នកាសារព័ត៌មានកម្ពុជាដឹកនាំដោយ)ជុំ កាណាលបជាតំណាងឱ្យរដ្ឋាភិបាល ហ៊ុន សែន តែទាំង២នាក់បានយល់ព្រមឱ្យ"ប៊ែនី"បង្កើតសាលាកាសែតខ្មែរមួយនៅសាកលវិទ្យាល័យ "ភ្នំពេញ" រៀបចំកម្មវិធីដោយសាស្ត្រាចារ្យ "ម៉ាយ ហ្វល័រ" នឹងមាន សុខឃាង ជាអ្នកបកប្រែភាសាផង ហើយនឹងក្លាយជាអនាគតគ្រូបង្រៀនអ្នកកាសែតជាភាសាខ្មែរផង-ពេលនោះមាន ប្រេត អាដាម ជាជំនាញការច្បាប់នៃអង្គការសិទ្ធិមនុស្សជាអ្នកសម្របសម្រួល រីង សម



Bernard Krisher & Family

បូរិន ជាបុគ្គលិកស្ថានទូតខាងមូលនិធីជាអ្នករៀបចំសំណើរសុំថវិការពី"អេស៊ាហ្វុង ដេស្យុង"។ អ្នកទាំងនោះ បានបញ្ចេញគុណសម្បត្តិតាមគម្រោងរបស់"ប៊ែណា គ្រីស័រ"បង្កើតបានជាសាលាបានយ៉ាងឆាប់រហ័ស ហើយដែលបញ្ចប់ជម្លោះអ្នកកាសែតឯករាជ្យនឹងអ្នកកាសែតរដ្ឋាភិបាលបាន, ថែមទាំងស្លបានជាថ្នាលអ្នកកាសែតវិជ្ជាជីវៈបានច្រើន នាក់ចេញពីមហាវិទ្យាល័យ"ភ្នំពេញ"ផង។

កាសែត"ដឹខាបូឌាដេលី"បានត្រូវកាន់កាប់បន្តដោយកូនស្រីរបស់"ប៊ែនី"ដែលមានជំនាញជាអ្នកសារព័ត៌មានដូចឪពុក នៅពេល"ប៊ែនី"ចូលនិវត្តន៏គឺ"ឌេប៊ី គ្រីស្ហ័រ"តែមិនយូរប៉ុន្មាន ក៏ត្រូវបិទទ្វារដោយអយុត្តិធម៌ ដោយរដ្ឋាភិបាលភ្នំពេញមិនអាចប្រឈមមុខនឹងសារព័ត៌មានសេរីបាន ក៏រកលេសបិទគ្រប់អង្គការពត័មានសេរីទាំងអស់ចេញពិកម្ពុជា នៅឆ្នាំ២០១៧ តែកេរ្តិ៍ឈ្មោះរបស់"ប៊ែណា គ្រីស័រ"មិនបានរលាយទៅជាមួយគ្នានោះឡើយ ។ អ្នកកាសែតនឹងពលរដ្ឋខ្មែរនឹងនៅចងចាំពីលោក"ប៊ែណា គ្រីស ហ័រ"យូរអង្វែង ដោយសារចិត្តសប្បុរស ដ៏ស្មោះស្ម័គ្រគ្មានល្អក់ពណ៌ចំពោះកម្ពុជានោះ។



# DIVERSITY

## ADULT DAYCARE CENTER

*"A place where your loved ones can call home"*

**What is Adult Day Care:**
We understand that being a fulltime caregiver is a difficult job. When an elderly loved one needs additional care or supervision during the morning or day, it can create stress for the caregivers of the family. Many families think they have no choice but to quit their jobs or to admit their loved ones into a nursing home or assisted living facility. Diversity Adult Daycare Center (DADC) provides a safe supervised community where elderly adults can socialize, enjoy activities and get assistance with personal care. This will allow the caregivers of the family to have peace of mind when they have an appointment, work obligations or simply to enjoy some personal time.

**Benefits of Adult Day Care for Elderly Adults:**
Attending Adult Day Care has many positive benefits for elderly adults. Your loved ones do not have to be at home feeling lonely with no mental stimulation, when the caretakers are occupied. Being in an Adult Day Care creates a feeling of being in a community, where they can have fun and stay healthy with many activities. Your loved ones will look forward to having their independence and meeting their friends. Having friendships that you see every day promotes feelings of self-worth and camaraderie.

**Services we offer at DADC:**
- Nutritious meals and snacks
- Group fitness classes
- Education classes
- Group field trips and outings
- Fun daily entertainment and activities
- Assistance with personal care
- Salon service
- Transportation
- Monthly birthday parties
- Medical staff
- Gardening

**Who is an ideal candidate for Adult Day Care:**
- 55 years and older
- Southeast Asians & Hispanic
  (we are handicap accessible)

**Forms of payment that we accept:**
- We accept private pay
- All major insurances accepted

433 Elmwood Ave. Providence, R.I 02907
P: 401-427-1337 | F: 401-369-7818
www.diversityadc.com | diversityadc@gmail.com

**Se Habla Español**

We speak English, Spanish, Khmer, Lao, Hmong, Portuguese, Russian and Tagalog.
Come and schedule a free tour of our facility. We will provide free assessment and application assistance.
All major insurances and private pay accepted. Medicaid pays for adult day care, there is no cost to you.

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

**AccuCare**
Home Care Agency
Group Adults Foster Care Program

កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើងដែលមានបញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរា ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្តល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។





**បើចង់អាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- រស់នៅផ្ទះរដ្ឋ
- អាយុ ២២ ឆ្នាំឡើងទៅ
- មាសហែលស្តង់ដា

**ផលប្រយោជន៍ទទួលបាន :**

- ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ
- ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក
- ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីជើ
- វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់
- សមាជិកអាចទាក់ទងមក២៤ម៉ោង

***To be eligibled for GAFC you must:***

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

***Benefits you will get:***

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្ដានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ

**ដើម្បីចុះឈ្មោះសូមទាក់ទងមក**
To register, please contact:
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

តមកពីទំព័រទី ០១

# ត្រៀមខ្លួនចូលឆ្នាំថ្មី ឆ្នាំកុរ...

ទី១៤មេសា២០១៩ វេលាម៉ោង ៣នឹង១២ រសៀល ខាងមុខនេះ ជាសញ្ញានៃការចូលឆ្នាំថ្មីពេលនោះឯង។

កាសែត"ខ្មែរផុសសហរដ្ឋអាមេរិក"សូមជូនពរនាឱកាសប្រកបដោយនក្ខត្តឬក ដែលគ្រប់វត្តអារាមនាំគ្នាអុជធូប សូត្រធមិ, នៅតាមផ្ទះសម្បែងមានការសែនព្រេន ដាក់ទានដោយក្តីស្រឡាញ់រាប់អាន តែងលំអដោយផ្ការភ្ញី... សូមឱ្យបារមីទាំងឡាយនោះ





រៀបចំទទួលទេវតា

ផ្តល់ជូនដល់លោកអ្នកអានៈ បើប្រកបមុខរបរអ្វី ឱ្យបានជួបតែជោគជ័យ, បើធ្វើការជានយោជក ក៏សូមឱ្យមានការតម្លើងប្រាក់បៀវត្សឱ្យបានខ្ពស់, បើជាអ្នកឯកទេសក្នុងជំនាញណាមួយ ក៏សូមឱ្យទទួលកិច្ចសន្យាក្រាស់ក្រែល, បើជាអ្នកព្យាករ ជាហោរា ជាអាចារ្យ ឬក៏ជាព្រះសង្ឃ ក៏សូមឱ្យពូកែរឆុតមាត់ទិញមើលធ្លុះ, បើជាមនុស្សធម្មតា ធំឬតូច ស្រីឬប្រុស ចាស់ឬក្មេង ក៏សូមឱ្យអ្នកទាំងនោះប្រកបតែនឹងពុទ្ធពរ ក្លាយជាមនុស្សដ៏ឆ្នើម រកសេចក្តីសុខជូនអ្នកដ៏ទៃ មានសេចក្តីសុខសោមនស្ស កុំបីឃ្លាងឃ្លាតឡើយ - សូមឱ្យពេលវេលាលោកអ្នកក្លាយជាការរៀនសូត្រ នូវចំណេះថ្មីៗជាទ្រព្យសម្បត្តិពូនឡើងដោយឯកឯង សូមឱ្យគ្រួសារ បងប្អូនកូនចៅ ប្រកបដោយសេចក្តីសុខដុមរមនានឹងសូមឱ្យបុព្វបុរសដែលកូនចៅនឹកគុណរាល់ថ្ងៃមកជួយថែររក្សាកូនចៅគ្រប់ៗពេលគ្រប់នាទី...។

សូមលោកអ្នកអាន នៅកន្លែងណាក៏ដោយ "អនុមោទនា ទទួលយកមកនូវផលកុសលនៃ"ពិធីបុណ្យចូលឆ្នាំកុរ"២៥៦៣នៃពុទ្ធសករាជ្យត្រូវនឹងឆ្នាំ២០១៩នៃគ្រឹស្តសករាជ្យ ចាប់ពីពេលនេះទៅ" ឱ្យបានគ្រប់ៗគ្នា ដែលនោះហើយជាវត្ថុបំណងរបស់"កបិលមហាព្រហ្ម" ក្នុងព្រះរាជដំណើរជុំវិញពិភពលោក ១ឆ្នាំម្តងដង្ហែរដោយព្រះរាជបុត្រី ព្រះនាង"ទុង្សទេវី"នាឆ្នាំនេះ។






# VeoRide launches new dockless bikeshare program in Lowell

Lowell, Mass. – VeoRide and the City of Lowell celebrated the launch of the new dockless bike-share program yesterday with a ribbon-cutting ceremony in front of City Hall. Representatives from the City of Lowell, VeoRide and other local organizations were on hand to talk about the bikeshare, demonstrate how it works, and what it will mean to the community.




Ribbon Cutting ceremony at Launch of Veoride, Lowell City Hall on 4/2; posed City Councilor Vesna Noun with Aiden Pin. Photo by Soben Pin

"We are proud to partner with the City of Lowell, and we have been so encouraged by the enthusiastic response by the community – even before we officially launched the bikeshare program here," said Ezra Richardson, VeoRide fleet manager-Lowell. "Our mission is to unlock the joy of riding, whether it's purely for an exercise break during the day, or just a quick errand."

VeoRide provided an initial fleet of 180 teal-colored pedal bikes at no cost to the City. That number could grow, based on demand. The bikes are accessible through the VeoRide app, which enables riders to rent bikes for $0.50 for each 15 minutes of use, or individuals may purchase a Day Pass for $6.99 for 24 hours of unlimited 2-hour rides. Monthly and Annual memberships are also available for Lowell residents and visitors, and university students are offered discounted membership rates. Dozens of Lowell residents signed up for memberships on the first day, and VeoRide anticipates that trend will continue.

The bikes are easy to use. Just open the VeoRide app to find an available bike; scan the QR code or enter the bike's ID number to unlock it; and go. When you're finished with your ride, simply park in a designated area, side the lock on the back of the bike closed, and that will end your trip and the fare.



# The Points of Light Lantern Festival is back for its 3rd year!

By Laura Tavares

Taking place the evening of Saturday, May 4th, Points of Light is a spring celebration of unity and renewal that brings together the diverse food, music, and traditions of Lowell's diverse cultures. The centerpiece of the night is a special ceremony in which participants personalize water lanterns that will be released onto the Western Canal, creating hundreds of floating points of light. The event will take place at Ecumenical Plaza (aprox 282 Suffolk St, Lowell).

Points of Light is planned by volunteers and local nonprofits donating staff time. The planning committee is open to the community and welcome to feedback. The event is entirely free thanks to donations, sponsorships, and volunteer time.

The planning committee is currently looking for volunteers to help before, during, and after the event. Visit www.pointsoflightlowell.com for more information, including how to decorate a lantern and to volunteer!



Photo credit: Thomas O'Hearn

COMM UNITY TEAM WORK

"កិច្ចប្រជុំក្រុមប្រឹក្សា"

កិច្ចប្រជុំប្រចាំខែរបស់ក្រុមប្រឹក្សា"កុំមូនីធី ទីមវើក" បានត្រូវកំណត់នៅថ្ងៃពុធ ទី២៧ មិនា ២០១៩ វេលាល្ងាច ម៉ោង៧គត់

នៅ១៥៥ផ្លូវមេរីម៉ាក ជាន់ទី២ បន្ទប់"ម៉ាជ្ជរី ម៉ាក់ឌឺរម៉ូទ"- សាធារណជនសូមស្វាគមន៍

BOARD MEETING

Community Teamwork monthly board meeting is scheduled on Wednesday, March 27th, 2019 at 155 Merrimack Street. Marjorie McDermott Board Room. 2nd Floor. Lowell, MA 01852. Meetings are called to order promptly at 7:00 P.M. Public is welcome.

ការិយាល័យ មេធាវី ថូមាស ស្តាលីយ៉ាណូស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com

ការិយាល័យច្បាប់
រ៉ូសា និង តាំង





Francisco J. Rosa, Esq.
មេធាវី ហ្វ្រាង់ ស៊ីស្កូ ជេ.រ៉ូសា

Andrew 'Bunna' Taing, Esq.
មេធាវី អែន ឌ្រីវប៊ុណ្ណា តាំង

Law Office of
Rosa & Taing
ATTORNEY AT LAW

SERVICES
- Auto Accidents/ Personal Injury
- Bankruptcy
- Immigration
- Consumer Protection
- Real Estate Closings/Disputes
- Divorces Child Custody

តំណាងក្តីដូចខាងក្រោម
- គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ
- ក្ស័យធន
- អន្តោប្រវេសន៍
- ការពារអតិថិជន
- ទិញលក់ផ្ទះអចលនទ្រព្យ
- លែងលះ និងអាណាព្យាបាលកុមារ

1550 Middlesex Street Lowell, MA 01851
Phone: 978-458-0934 | at@rosataing.com

Red Rose RESTAURANT

ភោជនីយដ្ឋាន ផ្កាកុលាបក្រហម ម្ចាស់ថ្មី -ម្ហូបឈ្ងុយឆ្ងាញ់

Pailin Plaza
716 Middlesex St. Ste 1
Lowell, MA 01851

អញ្ជើញមកចូលរួមមិន ខុសបំណងទេ សូមអរគុណ!

Mon-Sun
8am -8pm



បាយសាច់ជ្រូកពងទាចៀន



គុយទាវភ្នំពេញ



មីកន្ធាំង



បបរគ្រឿង

*ម្ហូបឆ្ងាញ់ជាងមុន តែតម្លៃនៅថោក ដូចមុនដដែល
*សេវាកម្មរហ័សទាន់ចិត្ត និងរួសរាយរាក់ទាក់

(978) 452-5400



# ជួបបញ្ហាបង់ថ្លៃកម្តៅ?

## កម្មវិធីជំនួយឥន្ធនៈអាចជួយអ្នកបាន!*

*អាចមានលក្ខខណ្ឌខ្លះ

រាល់ឆ្នាំអង្គការ Community Teamwork ផ្តល់ជំនួយឥន្ធនៈដល់១២,០០០លំនៅដ្ឋាន ដែលជួបបញ្ហា ដោយសារចំណាយច្រើនលើថ្លៃកម្តៅ





COMMUNITY TEAMWORK

| ទំហំគ្រួសារ | ប្រាក់ចំណូល |
|---|---|
| 1 | $ 35,510 |
| 2 | $ 46,437 |
| 3 | $ 57,363 |
| 4 | $ 68,289 |
| 5 | $ 79,215 |
| 6 | $ 90,141 |

## សូមទាក់ទងដើម្បីណាត់ជួប

សូមទាក់ទងដើម្បីណាត់ជួប
ទូរស័ព្ទលេខ៖ ៩៧៨ ៤៥៩ ៦១៦១
អ៊ីនធើណិត៖ www.commteam.org
ចុចលើពាក្យ Fuel Assistance ពណ៌ខៀវ នៅលើគេ ខាងស្តាំដៃ

ការផ្សព្វផ្សាយនេះ គឺមានការជួយឧបត្ថម្ភពីកម្មវិធីជំនួយផ្នែកថាមពលសម្រាប់គ្រួសារមានចំណូលទាប តាមរយៈថវិការដែលបានមកពីក្រសួងអភិវឌ្ឍន៍សហគមន៍ និងលំនៅដ្ឋានម៉ាសាឈូសេត។

ជំនួយនេះផ្តល់តាមសហគមន៍ដូចខាងក្រោម

| | |
|---|---|
| Arlington | Groton |
| Bedford | Lexington |
| Belmont | Lowell |
| Billerica | Pepperell |
| Burlington | Tewksbury |
| Carlisle | Tyngsboro |
| Chelmsford | Waltham |
| Dracut | Watertown |
| Dunstable | Westford |

Wilmington

( មានទឹងក្រ )

# "ថាមពលពន្លឺថ្ងៃ" ជួយសន្សំលុយបានច្រើន

ដោយ ពិន សំខុន

មិនមែនមានតែ"ម៉ាស៊ីនភ្លើង"ទេ ដែលបង្កើត "អគ្គិសនី"បាននោះ ឥឡូវនេះ"ពន្លឺថ្ងៃ"ក៏បង្កើតជាអគ្គិសនីបានដែរ គេហៅថា"ឋាមពលពន្លឺថ្ងៃ ឬ Solar Energy"។ "ម៉ាស៊ីនភ្លើង"គេប្រើ"ប្រេងសាំង" ដែលគេត្រូវចាយលុយដើម្បីទិញសាំង,ចំណែក "ថាមពលពន្លឺថ្ងៃ"វិញ គេប្រើពន្លឺថ្ងៃ ដូច្នេះពន្លឺនោះ "មិនចាំបាច់បង់ថ្លៃទិញ"វាទេ បើយើងប្រើ"អគ្គិសនីពន្លឺថ្ងៃ"ទៅវិញនោះ។

នា១០ឆ្នាំចុងក្រោយនេះ ផ្ទាំងចាប់ពន្លឺថ្ងៃមកធ្វើឱ្យទៅជាអគ្គិសនី សម្រាប់ប្រើប្រាស់ក្នុងផ្ទះ មានការជឿនលឿនសម្បើមណាស់ ហើយរដ្ឋបាលម៉ាសាឈូសិត គេលើកទឹកចិត្តពលរដ្ឋគេជាម្ចាស់ផ្ទះ ឬក៏ជាអ្នកជួលផ្ទះឱ្យប្រើ"អគ្គិសនីពន្លឺថ្ងៃ"ទាំងអស់គ្នាទៀតផង ពីព្រោះវានឹងជួយដល់ប្រជាពលរដ្ឋក្នុងគ្រួសារអាចសន្សំប្រាក់រាប់ពាន់ដុល្លាក្នុង១ឆ្នាំៗថែមទៀត ។

អាជីវករមានអាជ្ញាប័ណ្ណឈ្មោះ ចម្បា ប៉ាង មានសញ្ជាតិខ្មែរម្នាក់ និយាយពន្យល់អំពី Solar Energy ថា: - គេអាចជួលសម្រាលតម្លៃប្រើអគ្គិសនីរៀងរាល់ខែរហូតដល់៤០% - គេនឹងដាក់ផ្ទាំង "សូឡា" នៅលើដំបូល ដោយមានការពិនិត្យកែរដំបូលចាស់ឱ្យមានភាពរឹងមាំដើម្បីឱ្យទទួលទម្ងន់ថ្មីបានប្រសើរដោយមិនគិតថ្លៃ -មានការប្តូរប្រព័ន្ធខ្សែភ្លើងថ្មីសម្រាប់ផ្ទះចាស់ៗក៏មិនអស់សោហ៊ុយ -បើផ្ទះអ្នកគ្មានដំបូលក៏គេមានទីធ្លានៅទីដីទៃ សម្រាប់ដាក់ផ្ទាំង"សូឡា"ឱ្យបានដែរ...។ លោកអ្នកអាចជ្រើសយកផ្ទាំង"សូឡា"ក្នុងចំណោម៣ប្រភេទដែលមានគុណភាពស្រូបយកពន្លឺថ្ងៃបានខ្លាំងខុសគ្នា សម្រាប់ឱ្យស្របតាមសេចក្តីត្រូវការក្នុងផ្ទះនិមួយៗ ហើយបើមានដើមឈើធំៗ នៅក្បែរផ្ទះ ចង់កាត់ចោលគេអាចជួយធ្វើឱ្យបានដោយគ្មានយកប្រាក់ពិសេស មានការលើកពន្ធជូនជាកម្រៃច្រើនពាន់ដុល្លារផង ។



ចំប៉ា ប៉ាន់



ផ្ទះទើបនឹងដាក់ថាមពលពន្លឺថ្ងៃថ្មី



លោក ឆលី យី គ្រួសារខ្មែរម្នាក់ នៅផ្លូវ"ស្កូល" ទើបនឹងដាក់"សូឡា"ប្រើអគ្គិសនីពន្លឺថ្ងៃ បាន៣ខែ ហើយទើបតែប្រើមិនបានយូរប៉ុន្មានផង ក៏ខែក្តៅមកដល់ល្មម ប៉ុន្តែទោះជាប្រើបានតិចតួចក្តីគ្រួសារលោកមានការរីករាយណាស់ ដោយតម្លៃប្រើភ្លើងអគ្គិសនីបានធ្លាក់ចុះជាច្រើនរយដុល្លារ ដូចដែលបានគ្រោងទុកនោះមែន។ ។តែកូរចាំថា"ខែក្តៅគឺជាឱកាសល្អបំផុតសម្រាប់ផ្តើមប្តូរឋាមពលប្រេងម៉ាស៊ីន ឱ្យទៅ "ថាមពលពន្លឺថ្ងៃ"នោះហើយ ពីព្រោះតែបើកាត់ចរន្តនៅខែរងារមុខជារំខានអ្នកផ្ទះមានទាំងកូនក្មេង ដោយត្រូវកាត់ចរន្តអគ្គិសនីច្រើនថ្ងៃជាមិនខាន ។ ប្រើ"ថាមពលពន្លឺថ្ងៃ"មិនត្រឹមតែជួយថវិការគ្រួសារទេ ថែមទាំង ជួយមនុស្សជាតិឱ្យមានបរិឋានបរិសុទ្ធទៀតផង ។

សូមសួររក ចប្បា ប៉ាង ដើម្បីឱ្យជួយពន្យល់ពី"ថាមពលប្រើពន្លឺថ្ងៃ" បើទោះជាមមិនទិញក៏ដោយ (978)337-8644 ។

ក្រុមហ៊ុនអចលនៈទ្រព្យ អឺប៊ីន រាលអ៊ីស្តេក
URBAN REAL ESTATE
មជ្ឈមណ្ឌលផ្តល់សេវា ជួលលំនៅដ្ឋាន
Residential Leasing Center

ដាញ៉េល តាន ភ្នាក់ងារអចលនៈទ្រព្យ
Daniel Tan
Real Estate Agent
Cell: 978-902-6354
508 Westford Street • Lowell, MA 01851
(978) 454-0444

ក្រុមហ៊ុនធានារ៉ាប់រង ឃេឃេ អ៊ីនសួរិន អេជេនស៊ី
KK Insurance Agency, Inc.
រថយន្ត • លំនៅដ្ឋាន • អាជីវកម្ម
Car • Home • Business
508 Westford Street
Lowell, MA 01851
978-970-2212
kk@kkinsurancema.com


LEGEND
MOTOR GROUP, INC.
ហាងជួលជុលរថយន្ត លេជេន
មានសេវាជួលជុលរថយន្តគ្រប់ប្រភេទ
រយន្ត ប៉ះ បុក ខូចខាត និងក្រពិតមែន រឺទេ ?
ទូរស័ព្ទ 978-458-2085
COLLISION REPAIR
BEEN IN AN ACCIDENT?
FROM DENTS TO TOTALED,
WE CAN FIX IT ALL.

យើងរៀបចំសណ្តោងរថយន្ត នៅពេលត្រូវការ, ធ្វើការជាមួយនឹង
ក្រុមហ៊ុនធានារ៉ាប់រងរបស់លោកអ្នកនិងរៀបចំរាល់ឯកសារទាំងអស់។
ការពេញចិត្តរបស់លោកអ្នក គឺជាអាជីវកម្មរបស់យើង។
115 Rock St. Unt #7 Lowell, MA 01854

ព័ត៌មានខ្លីៗ

# ស.រ.អា.- សេចក្តីរាយការ"មូល័រ"

អ្នកស៊ើបអង្កេតពិសេស គឺលោក"មូល័រ" កាលពីថ្ងៃទី៣០ មិនា សម្រាប់ករណីលោកប្រធានាធិបតី "ឌុណល ត្រម"ថា "មានជាប់ទាក់ទងនឹងសកម្មភាពចារកម្មប្រទេសរុស្សី តាមប្រព័ន្ធកុំព្យូទ័រ មកលើការ



លោក មូល័រ ប្រធានាធិបតី ត្រម លោក បា

បោះឆ្នោតប្រធានាធិបតីនៅស.រ.អា. កាលពីឆ្នាំ ១៩១៦" ដោយបង្រួមសេចក្តី ជូនទៅលោករដ្ឋមន្ត្រីក្រសួងយុត្តិធម៌"បារ" តែបានបញ្ចប់ទៅយ៉ាងគួរឱ្យភ្ញាក់ផ្អើល ដោយសេចក្តីរាយការនោះនិយាយថា"លោក ឌុណល ត្រម ឥតមានទាក់ទងអ្វីជាមួយករណីចារកម្មរុស្សី នោះទេ", នៅពេលដែល២ឆ្នាំចុងក្រោយនេះ ព័ត៌មានជាច្រើនបានរាយការពីជំនួបគ្រួសារលោក ត្រម ជាមួយនឹងមន្ត្រីរុស្សីច្រើនដង។

សភាអាមេរិកាំងមិនបានរីករាយនឹងព័ត៌មាននៅក្នុងសេចក្តីរាយការ"មូល័រ"នេះទេ គេបានបោះឆ្នោតទាមទារឱ្យយកសេចក្តីរាយការលំអិត( មិនមែនបង្រួមសេចក្តី) ពីលោករដ្ឋមន្ត្រីយុត្តិធម៌ មកពិនិត្យដោយខ្លួនឯង។ បន្ថែមពីលើនេះ សភាដំណាងរាស្ត្រមានការសង្ស័យទៅលើការបង់ពន្ធមិនត្រឹមត្រូវរបស់លោក ឌុណល ត្រម ហើយគេក៏បានទាមទាររកការប្រកាសប្រាក់ជាប់ពន្ធពីក្រសួងពន្ធដាររបស់លោក ត្រម ជាមួយគ្នាមកពិនិត្យទៀតផង។

# ឡូវែល -ឧទ្យាន"ក្លេមិនតេ-Clemente Parc" នឹងក្លាយជាឧទ្យាន"ប៉ៃលិន-Pailin Parc"

ឧទ្យាន"ក្លេមិនតេ"ជាឈ្មោះដ៏ល្បីល្បាញរបស់កីឡាករស្បានីសម្នាក់ ដែលស្ថិតនៅចំកណ្តាល "ក្រុងខ្មែរ" បានត្រូវស្នើ កាលពីថ្ងៃទី២៦ មិនា២០១៩ ដោយលោក រ៉តនី អេលីយ៉ុត សមាជិកក្រុមប្រឹក្សាក្រុងឡូវែល អមដោយលោក វ៉ាសនា នួន អភិបាលក្រុងរងឡូវែល ឱ្យអាចប្តូរទៅជាឧទ្យាន"ប៉ៃលិន"ជាឈ្មោះតំបន់មួយនៃប្រទេសកម្ពុជា ដោយយោងទៅតាមការចូលចិត្តហៅឈ្មោះនេះ របស់ប្រជាពលរដ្ឋរស់នៅ "ក្រុងខ្មែរ"នៃក្រុងឡូវែល ហើយក្នុងចំណោមឧទ្យានចំនួន៩៤ នៅជុំវិញឡូវែលនេះក៏ពុំទាន់មានឈ្មោះណាមួយជាឈ្មោះខ្មែរដែរ។

នាថ្ងៃប្រជុំដ៏ពិសេសសម្រាប់ពលរដ្ឋខ្មែរនោះ ក៏មានការចូលរួមយ៉ាងកុះករពីខ្មែរនៅឡូវែលដែរ ប៉ុន្តែសមាជិកក្រុមប្រឹក្សាក្រុងមិនបានធ្វើសេចក្តីសម្រេចចិត្តពេលនោះទេ ដោយទុកឱ្យគណកម្មការគ្រប់គ្រងឧទ្យានជាអ្នកសម្រេចវិញនៅពេលក្រោយ ។

ដូច្នេះបើចង់បានឧទ្យាននោះ មានឈ្មោះជាខ្មែរ គួរបងប្អូនបន្តបញ្ចេញយោបល់ឱ្យសាលាក្រុងបានឮសម្លេង -លោកស្រី រីដា ម៉ែស្មៀ មិនបានគាំទ្រសំណើរថ្មីនោះទេ ដោយសារតែធ្លាប់គាំទ្រឈ្មោះដើមឱ្យសហគមន៍"ស្បានីស" ហើយឈ្មោះនោះក៏មិនមែនជាឈ្មោះ"វិរបុរសខ្មែរ"ដែរ, តែលោក អេលីយ៉ុត បានឱ្យដឹងថាសហគមន៍"ស្បានីស" គេមិនបានជំទាស់នឹងសំណើរនេះទេ ដោយសារគេមានឈ្មោះ"វិរបុរស" របស់គេ នៅឧទ្យានផ្សេងៗទៀត ច្រើនណាស់ហើយ។

# ឡូវែល-ជំនួយសិក្សាក្រៅម៉ោង

លោកអ្នកមានកូនចៅរៀនពីថ្នាក់ទី១ ដល់ទី ១២ ហើយត្រូវការឱ្យមានការជួយបង្រៀនបន្ថែមលើកម្មវិធីសាលារៀនទាំងឡាយនោះ ។ សមាគម "អេសេឡិក"មានកម្មវិធី"IXL"តាមប្រព័ន្ធកុំព្យូទ័រ ស្របនឹងការបង្រៀននៅសាលាកូនចៅលោកអ្នក ដើម្បីឱ្យកូនចៅអាចរៀនបន្ថែមបាន តាមពេលវេលាដែលមាន ហើយមានគ្រូតាមដានទូវគ្រប់មេរៀនដែលកូនអ្នករៀននៅសាលារបស់ពួកគេបាន ។



លោកអ្នកជាមាតាបីតានឹងទទួលបានទូវសេចក្តីរាយការជាលាយលក្ខអក្សរពីគ្រូដឹកនាំកម្មវិធីក្នុង១ខែ២ដង ដើម្បីឱ្យដឹងពីការជឿនលឿនរបស់កូន ចៅលោកអ្នក។ តម្លៃសិក្សា៣០ ដុល្លាក្នុង១ខែ ។ ដំណឹងបន្ថែមសូមទូរស័ព្ទរកលេខ ៩៧៨-៩៤២ ១៦៤១ ។






# ស្វែងយល់ពីប្រវត្តិនៃបុណ្យចូលឆ្នាំថ្មីប្រពៃណី ជាតិខ្មែរ!

បុណ្យចូលឆ្នាំថ្មី គឺជាបុណ្យប្រពៃណីជាតិដ៏ធំរបស់ប្រជាជនខ្មែរ។ ឆ្នាំថ្មី ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ គ្រិស្តសករាជ២០១៩នេះ ត្រូវចូលមកដល់នៅថ្ងៃសៅរ៍១៤រោច ខែចេត្រ ត្រូវនឹងថ្ងៃទី១៤ ខែមេសា គ.ស.២០១៩ វេលាម៉ោង០៣:១២នាទីរសៀល។

ទេវតាឆ្នាំថ្មីនេះព្រះនាម "ព្រះនាងទុង្សទេវី" ជាបុត្រីទី១នៃកបិលមហាព្រហ្ម គង់នៅចាតុម្មហារាជិកាទ្រង់អម្ពរពណ៌ខៀវ លម្អនៅព្រះកាណ៌ ដោយបុប្ផ "ត្រកៀត" អភរណៈ "និលរតន៍" ភក្សាហារទ្រង់ "សាច់ទ្រាយ" ព្រះហស្តស្តាំទ្រង់ "កងចក្រ" ព្រហស្តឆ្វេងទ្រង់ "ត្រីសូល៌" ទ្រង់គង់រំពៃឈរលើខ្នង "ស្តេចក្ងោក" (មយូរា) ដែលជាបាហនៈ។

ដើម្បីចូលរួមអបអរ ដល់ពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ យើងសូមលើកយកនូវប្រវត្តិបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាខ្មែរ ជូនប្រិយមិត្តអ្នកអានស្វែងយល់ដូចខាងក្រោម:

*** ប្រវត្តិបុណ្យចូលឆ្នាំថ្មី:**

តំណាលថា កាលដើមនៃភទ្ទកប, មានសេដ្ឋីនាយម្នាក់មានបុត្រម្នាក់ ឈ្មោះ ធម្មបាលកុមារ ជាអ្នកមានចំណេះវិជ្ជាដ៏វិសេសវិសាលរៀនចេះចប់គម្ពីរត្រៃវេទ តាំងពីអាយុ៧ឆ្នាំមកម្ល៉េះ។ សេដ្ឋីនាយជាបិតាបានសាងប្រាសាទមួយ ឱ្យនៅទៀបដើមជ្រៃមួយដ៏ធំ ក្បែរឆ្នេរទន្លេដែលជាទីនៅនៃបក្សីទាំងឡាយ។ ធម្មបាលកុមារនោះ បានចេះទាំងភាសាបក្សីទាំងពួងផង ហើយក្លាយជាអាចារ្យសម្តែងមង្គលផ្សេងៗដល់មនុស្សទាំងពួងផងដែរ។

គ្រានោះ មនុស្សលោករមែងរាប់អានព្រះមហាព្រហ្ម និងកបិលមហាព្រហ្មមួយអង្គទៀត ដែលជាអ្នកសម្តែងមង្គលដល់មនុស្សទាំងពួងដូចគ្នាដែរ។ ពេលនោះ កបិលមហាព្រហ្មបានជ្រាបព័តិមានរឿងធម្មបាលកុមារ ក៏ចុះមកសួរបញ្ហាជាមួយចៅធម្មបាលកុមារនូវប្រស្នាចំនួន៣ខ ដោយទ្រង់ដាក់លក្ខខណ្ឌថា "បើចៅដោះប្រស្នារបស់យើងបាន យើងនឹងកាត់ព្រះសិរសាបូជាជូនចៅឯង តែបើចៅឯងដោះប្រស្នាយើងមិនរួចទេ ចៅឯងត្រូវកាត់ក្បាលថ្វាយដល់យើងវិញ"។ ធម្មបាលកុមារក៏សុំឱ្យពន្យារពេលចំនួន៧ថ្ងៃសិនដើម្បីគិតដោះប្រស្នា។

លុះកន្លងទៅ៦ថ្ងៃហើយ ក៏នៅតែគិតមិនឃើញ ចៅធម្មបាលកុមារដឹងខ្លួនថា ព្រឹកស្អែកនឹងត្រូវស្លាប់ដោយអាជ្ញាកបិលមហាព្រហ្ម ជាប្រាកដហើយ។ ដូច្នេះគួរតែរត់ទៅលាក់ខ្លួនពួនអាត្មាសិនប្រសើរជាង។ គិតហើយ ធម្មបាលកុមារបានចុះពីប្រាសាទ ទៅដេកពួននៅក្រោមដើមត្នោតមួយដើម។ ដើមត្នោតនោះមានសត្វឥន្ទ្រីញី-ឈ្មោល ធ្វើសំបុកអាស្រ័យនៅ។

វេលាយប់ឥន្ទ្រីញីសួរទៅឥន្ទ្រីឈ្មោលថា "ព្រឹកនេះយើងបានអាហារពីណាស៊ី? ឱ្យឥន្ទ្រីឈ្មោលឆ្លើយថា "យើងនឹងស៊ីសាច់ធម្មបាលកុមារ ដែលត្រូវកបិលមហាព្រហ្មសម្លាប់ ព្រោះដោះប្រស្នាមិនរួច"។ ឥន្ទ្រីញីសួរទៀតថា "ប្រស្នានោះ ដូចម្តេច?", ឥន្ទ្រីឈ្មោលឆ្លើយថា "ប្រស្នានោះមាន៣ខ: ខទី១ ពេលព្រឹកសិរីសួស្តីឋិតនៅត្រង់ណា, "ខ" ទី២ ពេលថ្ងៃត្រង់សិរីសួស្តីឋិតនៅត្រង់ណា, និង "ខ" ទី៣ ពេលល្ងាចសិរីសួស្តីឋិតនៅត្រង់ណា"។

ឥន្ទ្រីញីសួរទៀត "ចុះសិរីសួស្តីទាំង៣ពេលនោះឋិតនៅត្រង់ណាទៅ?", ឥន្ទ្រីឈ្មោលឆ្លើយ "ខទី១ ពេលព្រឹកសិរីសួស្តីឋិតនៅលើមុខ ហេតុនោះ ទើបមនុស្សទាំងឡាយត្រូវយកទឹកទៅលប់មុខ, "ទី២ ថ្ងៃត្រង់សិរីឋិតនៅលើទ្រូង ហេតុនោះ ទើបមនុស្សត្រូវយកទឹកលាងទ្រូង, ខទី៣ ពេលល្ងាចសិរីស្ថិតនៅលើជើង ហេតុនេះ ទើបមនុស្សទាំងឡាយត្រូវយកទឹកលាងជើង"។

ធម្មបាលកុមារបានឮដូច្នេះ ក៏ត្រឡប់ទៅប្រាសាទវិញ។ ព្រឹកឡើងកបិលមហាព្រហ្ម ក៏ចុះមកសួរប្រស្នា ធម្មបាលកុមារក៏ឆ្លើយដោះត្រូវទាំង៣ខ។ តែមុននឹងកាត់ព្រះសិរសាដូចបានសន្យាគ្នា ព្រះកបិលមហាព្រហ្ម បានហៅទេពធីតាទាំង៧អង្គ ដែលជាបាទបរិចារិកាព្រះឥន្ទ្រ មកប្រាប់ថា "ឥឡូវ បិតាត្រូវកាត់ព្រះសិរសាបូជាជូនធម្មបាលកុមារ តែបើដាក់ព្រះសិរសាបិតា ទៅលើផែនដី នឹងកើតជាភ្លើងឆេះទាំងលោកធាតុ តែបើបោះទៅឰដ៏អាកាសភ្លៀងនឹងកើតគ្រោះរាំងស្ងួត ហើយបើចោលក្នុងមហាសមុទ្រ ទឹកនឹងរីងស្ងួតហួតអស់ ដូច្នេះសូមឱ្យបុត្រីទាំង៧អង្គយកពានមកទទួលព្រះសិរសាបិតា"។ ថាហើយក៏កាត់ព្រះសិរសា ហុចទៅឱ្យព្រះនាងទុង្សាទេវី ជាបុត្រីច្បង។


ពិធីពូនភ្នំខ្សាច់


ពិធីស្រង់ព្រះ


ពិធីរាប់បាត

ព្រះនាងទុង្សាទេវី ក៏យកពានទៅទទួលព្រះសិរសារបស់កបិលមហាព្រហ្ម ហើយដង្ហែរប្រទក្សិណជុំវិញភ្នំព្រះសុមេរុចំនួន៦០នាទី ហើយក៏អញ្ជើញទៅប្រតិស្ថានទុកក្នុងមណ្ឌលក្នុងគុហាគន្ធមាលី នៃភ្នំកៃលាសបូជាគ្រឿងទិព្វផ្សេងៗ ព្រះវិស្សកម្មទេវបុត្រ ក៏និម្មិតរោងទិព្វដ៏ប្រណិតអមដោយកែវ៧ពណ៌ឈ្មោះថា "ភគវតីសភា" ឱ្យជាទីប្រជុំនៃទេវតា លុះដល់គម្រប់១ឆ្នាំជាសង្ក្រាន្ត ទេពធីតាទាំង៧អង្គ ក៏ផ្លាស់វេនគ្នាមកអញ្ជើញ ព្រះសិរសាកបិលមហាព្រហ្ម ចេញមកដង្ហែរប្រទក្សិណភ្នំព្រះសុមេររៀងរាល់ៗឆ្នាំ ហើយត្រឡប់ទៅឋានទេវលោកវិញ។

***ឈ្មោះទេពធីតាមហាសង្ក្រាន្ត និងគ្រឿងអភរណៈ:**

**១:** បើសង្ក្រាន្តជាថ្ងៃអាទិត្យ ទេពធីតាព្រះនាម "ព្រះនាងទុង្សាទេវី" សៀតផ្កាទទឹម គ្រឿងប្រដាប់បទុមរាគ ភក្សាហារផ្លែឧទុម្ពរ (គ្រឿងសោយ) អាវុធស្តាំកងចក្រ ឆ្វេងខ្យងស័ង្ខ ពាហនៈជាសត្វគ្រុឌ។

**២:** បើថ្ងៃចន្ទ ទេពធីតាព្រះនាម "ព្រះនាងគោរាគទេវី" សៀតផ្កាអង្គារបុស្ស គ្រឿងប្រដាប់កែវមុក្តា (គជខ្យង) ភក្សាហារប្រេង អាវុធស្តាំព្រះខ័ឌ្គ ឆ្វេងឈើច្រត់ ពាហនៈសត្វខ្លា។

**៣:** បើថ្ងៃអង្គារ ទេពធីតាព្រះនាម "ព្រះនាងរាគសាទេវី" សៀតផ្កាឈូក គ្រឿងប្រដាប់កែវមោរ៉ា (ត្បូងកែវរាងមូល) ភក្សាហារលោហិត អាវុធស្តាំត្រីសូល៌ (លំពែងផ្លែ៣) ឆ្វេងធ្នូ ពាហនៈសត្វសេះ។

**៤:** បើថ្ងៃពុធ ទេពធីតាព្រះនាម "ព្រះនាងមណ្ឌាទេវី) សៀតផ្កាចម្ប៉ា គ្រឿងប្រដាប់ពិទូរ្យ (កែវ) ភក្សាហារទឹកដោះសិប្បិ អាវុធស្តាំម្ជុល ឆ្វេងឈើច្រត់ ពាហនៈសត្វលា។

**៥:** បើថ្ងៃព្រហស្បតិ៍ ទេពធីតាព្រះនាម (ព្រះនាងកិរិណីទេវី) សៀតផ្កាមណ្ឌា គ្រឿងប្រដាប់កែវមរកត (ត្បូងពណ៌បៃតង) ភក្សាហារសណ្តែក ល្ង អាវុធស្តាំកង្វេរ (ដង្កាវដីរ) ឆ្វេងកាំភ្លើង ពាហនៈសត្វដំរី។

**៦:** បើថ្ងៃសុក្រ ទេពធីតាព្រះនាម "ព្រះនាងកិមិរាទេវី" សៀតផ្កាចង្កុលនី គ្រឿងប្រដាប់បុស្សរាគ័ម ភក្សាហារចេកណាំវ៉ា អាវុធស្តាំព្រះខ័ឌ្គ ឆ្វេងពិណ ពាហនៈសត្វក្របី។

**៧:** បើថ្ងៃសៅរ៍ ទេពធីតាព្រះនាម "មហោធរៈទេវី" សៀតផ្កាត្រកៀត គ្រឿងប្រដាប់និលរតន៍ ភក្សាហារសាច់ទ្រាយ អាវុធស្តាំកងចក្រ ឆ្វេងត្រីសូល៌ ពាហនៈសត្វក្ងោក។

*** ទំនៀមចូលឆ្នាំ:**

កាលដើមឡើយខ្មែរយើងតែងប្រារព្ធធ្វើបុណ្យចូលឆ្នាំក្នុងខែមិគសិរ ព្រោះគេកំណត់យកខែនេះជាខែដើមឆ្នាំ។ នាសម័យព្រេងនាយឆ្នាំនីមួយៗ ចែកជា៣រដូវតាមចន្ទគតិ មានហេមន្តរដូវ (រដូវទឹកសន្សើម), គិម្ហរដូវ (រដូវក្តៅ) និងវស្សានរដូវ (រដូវភ្លៀង)។ បុរាណាចារ្យលោកគិតថា ហេមន្តរដូវចាត់ទុកជារដូវដើមឆ្នាំ ប្រៀបបាននឹងពេលព្រឹកដែលផុតពីរាត្រី គឺជាពេលព្រឹក។ គិម្ហរដូវ ចាត់ទុកជា

តទៅទំព័រទី ១៦


ល្បែងបោះអង្គុញ

តមកពីទំព័រទី ១៥

# ស្វែងយល់ពីប្រវត្តិបុណ្យចូលឆ្នាំថ្មី...

កណ្ដាលឆ្នាំ ប្រៀបបានជាពេលថ្ងៃត្រង់។ វស្សានរដូវ ជារដូវមេឃងងឹត មានភ្លៀងផ្គរ ចាត់ទុកជាចុងឆ្នាំ ប្រៀបបាននឹងពេលព្រលប់។

ទំនៀមពិធីចូលឆ្នាំប្រព្រឹត្តទៅចំនួន៣ថ្ងៃ។ ថ្ងៃដំបូងជាថ្ងៃមហាសង្ក្រាន្ត, ថ្ងៃទី២ ជាថ្ងៃវ័នបត និងថ្ងៃទី៣ ជាថ្ងៃឡើងស័ក។ ឯការកំណត់ខែ-ថ្ងៃ-ម៉ោង-នាទី ដែលឆ្នាំចាស់ត្រូវផុតកំណត់ ហើយទេវតាឆ្នាំថ្មីត្រូវចុះមកទទួលតំណែងពីទេវតាឆ្នាំចាស់នោះ គេអាចដឹងបានយ៉ាងទៀងទាត់ ដោយអាស្រ័យតាមក្បួនហោរាសាស្ត្របែបបុរាណ គឺក្បួនមហាសង្ក្រាន្ត នេះឯង។

**តើថ្ងៃចូលឆ្នាំថ្មីរបស់ខ្មែរយើង ត្រូវលើខែណា? ថ្ងៃណា?**

ចាប់ពីត្រឹមពីសម័យក្រុងអង្គរធំ (ប្រាសាទបាយ័ន) ឡើងទៅ ខ្មែរយើងប្រើឆ្នាំចន្ទគតិ (រាប់តាមដំណើរព្រះចន្ទ) ទើបកំណត់យកខែមិគសិរ (ជាខែទី១) ជាខែចូលឆ្នាំ ហើយខែកក្ដិក ជាខែទី១២។

លុះក្រោយមក ទើបគេនិយមប្រើសុរិយគតិ (រាប់តាមដំណើរព្រះអាទិត្យ) ជាសំខាន់វិញ ហើយកំណត់ចូលឆ្នាំក្នុងខែចែត្រ (ខែទី៥) ដែលជាឆ្នាំកំណត់ព្រះអាទិត្យចូលកាន់មេរាសី ហើយថ្ងៃចូលឆ្នាំរមែងត្រូវលើថ្ងៃទី១៣ នៃខែមេសា (ចែត្រ) រៀងរាល់ឆ្នាំ ប៉ុន្តែយូរៗទៅមានភ្លាត់ម្ដងៗ ចូលឆ្នាំក្នុងថ្ងៃទី១៤ ក៏មានខ្លះដែរ។ ការផ្លាស់ប្ដូរនេះ ព្រោះបុព្វបុរសយើងយល់ឃើញថា នៅខែមិគសិរនេះ ប្រជាកសិករ



ល្បែងទាញព្រ័ត្រ

ខ្មែររវល់មមាញឹកនឹងរបរកសិកម្ម មានស្រែចម្ការជាដើម ទើបលោកលើកកំណត់ពេលចូលឆ្នាំមកធ្វើនៅខែចែត្រវិញ ដោយហេតុថា ខែចែត្រកិច្ចការច្រូតការបោកបែន បានចប់សព្វគ្រប់ ហើយប្រជាពលរដ្ឋខ្មែរទំនេរ មានឱកាសធ្វើបុណ្យទានកម្សាន្តសប្បាយតាមប្រាថ្នា។

មហាសង្ក្រាន្តដែលប្រើរបៀបគន់គូរតាមសុរិយគតិ ហៅថា "សាមញ្ញសង្ក្រាន្ត" (ព្រះអាទិត្យដើរត្រង់ចំពីលើក្បាល ជាសង្ក្រាន្ត)។ មហាសង្ក្រាន្តដែលប្រើរបៀបគន់គូរតាមចន្ទគតិ ហៅថា "អាយន្តសង្ក្រាន្ត" (ពេលដែលព្រះអាទិត្យ ដើរបញ្ឈៀងមិនត្រង់ចំលើក្បាល)។ គេនៅប្រើចន្ទគតិឯបគ្នានឹងសុរិយគតិដែរ ព្រោះចន្ទគតិមានទំនាក់ទំនងនឹងពុទ្ធប្បញ្ញត្តិ



ល្បែងប្រជាប្រិយត្រុដិ

ច្រើន។ ចំណែកឯថ្ងៃចូលឆ្នាំតាមចន្ទគតិមិនបានទៀងទាត់ជាថ្ងៃណាមួយទេ ជួនកាលចូលឆ្នាំក្នុងវេលាខ្នើត ជួនកាលក្នុងវេលារនោចទៅវិញ។ ប៉ុន្តែនៅក្នុងរវាងមួយខែ គឺមិនមុនថ្ងៃ៤កើត ខែចែត្រ និងមិនហួសថ្ងៃ៤កើត ខែពិសាខទេ ដូចនេះ សង្ក្រាន្តខ្លះធ្លាក់ទៅក្នុងខែពិសាខក៏មាន។

ចំពោះពិធីផ្សេងៗ ខ្មែរយើងមានរៀបចំតាមប្រពៃណីដូចតទៅនៅពេលមុនចូលឆ្នាំ គេនាំគ្នាប្រុងប្រៀបរកស្បៀងអាហារ សម្អាតផ្ទះសំបែង រែកទឹកដាក់ពាងរកអុសទុកកាត់សម្លៀកបំពាក់ថ្មីៗជាដើម។ ថ្ងៃចូលឆ្នាំមកដល់ គេរៀបគ្រឿងសក្ការបូជាសម្រាប់ទទួលទេវតាឆ្នាំថ្មី មានបាយសីមួយគូ ស្លាធម៌១គូ ធូប៥ ទៀន៥ ទឹកអប់១គូ ផ្កាភ្ញី លាជ ទឹក១ផ្តិល និងភេសជ្ជៈ នំនែក ផ្លែឈើគ្រប់មុខ។ ចំណែកផ្ទះសំបែង គេតុបតែងរំលេចដោយអំពូលអគ្គិសនី ខ្សែតូចៗចម្រុះពណ៌ ឬចង្កៀងគោម គ្រប់ពណ៌សម្រាប់ទទួលទេវតាឆ្នាំថ្មី។

លុះដល់វេលាកំណត់ទេវតាថ្មី ចុះមកហើយ គេនាំកូនចៅអង្គុយជុំគ្នានៅជិតកន្លែងរៀបគ្រឿងសក្ការៈនោះ ហើយអុជទៀនធូប បាញ់ទឹកអប់ បន់ស្រន់សុំសេចក្ដីសុខចម្រើនគ្រប់ប្រការពីទេវតាថ្មី។ ចំពោះគ្រឿងសក្ការៈ និងក្រយាស្ងោយដាក់ថ្វាយទេវតានោះ គេនិយមតម្រូវតាមចិត្តទេវតា ដែលនឹងត្រូវចុះក្នុងឆ្នាំនីមួយៗ។

**ឧទាហរណ៍:** បើទេវតាដែលត្រូវចុះមកនោះសោយល្ង សណ្ដែក គេដាក់សណ្ដែក ល្ងថ្វាយ ឯពិធី៣ថ្ងៃនៃថ្ងៃចូលឆ្នាំនោះ

* **ថ្ងៃទី១:** គេយកចង្ហាន់ទៅប្រគេនព្រះសង្ឃនៅវត្ត។ ពេលល្ងាចគេនាំគ្នាជញ្ជូនខ្សាច់សាងវាលុកចេតិយ នៅជុំវិញព្រះវិហារ ឬនៅជុំវិញដើមពោធិ៍ណាមួយនៅក្នុងវត្តនោះ។នៅពេលព្រលប់គេប្រគេនភេសជ្ជៈដល់ព្រះសង្ឃនិមន្តលោកចម្រើនព្រះបរិត្តនិងសម្ដែងធម្មទេសនា។

* **ថ្ងៃទី២:** កូនចៅជូនសម្លៀកបំពាក់ នំចំណីលុយកាក់ដល់អ្នកមានគុណ មានឪពុកម្ដាយ ជីដូនជីតាជាដើម។ ជួនកាលគេធ្វើទានដល់មនុស្សបម្រើ ឬអ្នកក្រីក្រទៀតផង។ ពេលរសៀល គេនាំគ្នាទៅពូនភ្នំខ្សាច់ទៀត ហើយសូត្រធម៌អធិដ្ឋានភ្នំខ្សាច់ដែលគេសន្មត់ទុកដូចចូឡាមណីចេតិយ ហើយនិមន្តព្រះសង្ឃបង្សុកូលចេតិយបញ្ជូនមគ្គផលដល់វិញ្ញាណក្ខន្ធបងប្អូន ដែលបានស្លាប់ទៅ។

* **ថ្ងៃទី៣:** ពេលព្រឹក និមន្តព្រះសង្ឃឆ្លងភ្នំខ្សាច់ ពេលល្ងាចនិមន្តព្រះសង្ឃស្រង់ទឹក និងស្រង់ព្រះពុទ្ធរូប (តាមការនិយមនៃស្រុកខ្លះ) នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មីនេះ គេនាំគ្នាលេងល្បែងប្រជាប្រិយកម្សាន្តសប្បាយជាច្រើន ដូចជាលេងបោះអង្គុញ ចោលឈូង ទាញព្រ័ត្រ លាក់កន្សែង ចាប់កូនខ្លែងជាដើម និងមានរបាំត្រុដិ (ច្រើនមាននៅខេត្តបាត់ដំបង សៀមរាប) ជាពិសេសទៀត គឺរាំវង់តែអាស្រ័យទៅតាមការនិយមចូលចិត្ត របស់មនុស្សតាមតំបន់ ខ្លះនិយមនាំគ្នាដើរកម្សាន្តបន្ត ខ្លះនិយមធ្វើបុណ្យទាន-តាមវត្តអារាម។

ដកស្រង់ពី Feshnews



# មេធាវីថំមាសស្ទីលីអាណូស

- ជួយធ្វើតាក់ដោយមិនចាំបាច់មានលេខសូស្យាល់ (Filling Tax without Social Security)
- ជួយធ្វើគ្រីនកាត ១០ ឆ្នាំអោយបានបន្ទាប់ពីមានការលែងលះគ្នា (Divorced 10 year Green Card)
- ជួយធ្វើគ្រីនកាត ២ ឬ ១០ឆ្នាំ (Help with 2 or 10 year Green Card)
- ជួយអ្នកដែលនៅលើសកំណត់អោយបាននៅក្នុងប្រទេសបន្តទៀត (Help Overstay Bars)
- ជួយការពារកុំអោយគេបញ្ជូនទៅស្រុកវិញបន្ទាប់ពីបានប្រព្រឹត្តិខុសច្បាប់ (Criminal Deportation)
- ជួយរៀបចំឯកសារធានាឪពុកម្តាយកូននិងបងប្អូនមកអាមេរិច (Get Parents, Children and Sibling Here)
- ជួយរៀបចំឯកសារសំរាប់ធានាប្តីប្រពន្ធ ឬគូរដណ្តឹងមកអាមេរិច (Get Spouse or Fiancé Here)
- ជួយរៀបចំឯកសារសុំលែងលះប្តីប្រពន្ធ (Divorce, only in Massachusetts)
- ជួយការពារ និងធ្វើជាតំណាងក្នុងរឿងគ្រោះថ្នាក់ចរាចរណ៍ (Car Accident, only in Massachusetts)
- ជួយធ្វើការតវ៉ានៅចំពោះមុខក្រុមប្រឹក្សាសាលាឧទ្ធរណ៍ផ្នែកអន្តោប្រវេសន៍ (BIA Immigration Appeals)
- ជួយធ្វើឯកសារចូលសញ្ជាតិផល់សាម៉ីខ្លួន និងកូនៗរបស់លោកអ្នក (N-400 and N-600)
- ជួយធ្វើគ្រីនកាតថ្មីបន្ទាប់ពីត្រូវគេលួច ឬបាត់បង់ (I-90, Replacement Green Card)
- ជួយសុំកាតធ្វើការ (Work Card)
- ជួយធ្វើលិខិតធ្វើដំណើរចេញចូល (Re-entry Permit)

# Thomas Stylianos Law Offie

## 287 Appleton Street, Suit 205 Lowell, MA 01852

# Tel: 978-459-5000

## E-mail: Tom@stylianoslaw.com

Attorneys' only licensed in Massachusetts

# Boch Honda West

299 Littleton Rd, Westford, MA 01886
**EXIT 32 - OFF 495**

HOME OF THE 20 YEAR 200,000 MILE LIMITED POWERTRAIN ★ WARRANTY ★ BOCH

# ផ្តល់ជូនការធានា
## រយៈពេល 20 ឆ្នាំ/រយៈចំងាយ 200,000 ម៉ាយ

រួមបញ្ចូលរាល់ការទិញរថយន្តហុងដាសេរីថ្មីទាំងអស់!
លោកអ្នកអាចធ្វើដំណើរជុំវិញពិភពលោក 8 ដងហើយ នៅតែមានការការពារ!

ធានាមានរថយន្តថ្មីនៅក្នុងស្តុក លើកលែងតែប៉ុន្មានដាក់លក់មួយចំនួនប៉ុណ្ណោះ ហើយការធានា
គឺមិនអាចផ្ទេរការផ្ទេរបានឡើយ។ មិនមានសម្រាប់រដ្ឋល។
ជួបជាមួយអ្នកលក់សម្រាប់ព័ត៌មានលម្អិតនិងពិនិត្យមើលនៅកន្លែងលក់។

## ផ្តល់ជាពិសេសសម្រាប់ធ្វើម្ចាស់ជាមុន

Honda dream garage spring event

Pre-Owned 2012 Jeep **COMPASS LATITUDE** VIN: CD562925 **$8,488**




Pre-Owned 2017 Ford **FOCUS SE** VIN: HL247316 **$9,988**




Pre-Owned 2017 Toyota **COROLLA LE** VIN: HC907514 **$12,388**




Pre-Owned 2015 Honda **CIVIC LX** VIN: FE073159 **$12,988**




Pre-Owned 2018 Kia **SOUL** VIN: J7506189 **$12,988**




Pre-Owned 2008 Jeep **WRANGLER** VIN: 8L504323 **$14,888**




Pre-Owned 2016 Honda **ACCORD LX** VIN: GA106903 **$15,500**




Pre-Owned 2016 Honda **CR-V** VIN: GL024012 **$18,888**




Pre-Owned 2016 Honda **ODYSSEY** VIN: GB064058 **$22,488**




Pre-Owned 2018 Chevrolet **SILVERADO 1500 DOUBLE CAB** VIN: JZ338998 **$27,488**




Pre-Owned 2016 Audi **Q5 PREMIUM PLUS** VIN: GA074488 **$28,888**




Pre-Owned 2019 Infiniti **QX60 AWD** VIN: KC520726 **$36,888**




រាល់តម្លៃដែលបានផ្សព្វផ្សាយ មិនរួមបញ្ចូលពន្ធ និងការបង់ថ្លៃផ្សេងៗដល់រដ្ឋាភិបាល, ការចំណាយលើការរត់ការទទួលកំណាទាន, ការបង់លើការរៀបចំឯកសារផ្សេងៗរបស់អ្នកលក់, បង់ថ្លៃរៀបចំឯកសារ បង់ពន្ធតាមប្រព័ន្ធអេឡិចត្រូនិច និងការបង់ថ្លៃលើការធ្វើតេសការបំភាយឧស្ម័នរបស់រថយន្ត។ សូមជួបអ្នកលក់សម្រាប់ព័ត៌មានបន្ថែម។ ការផ្តល់ជូននេះ ផុតកំណត់នៅ 4/30/19។

## SERVICE SPECIALS

**$49.95** ផ្លូវប្រេងនិងតម្រង់ប្រេង, តំរង់កង់ឡាន, ពិនិត្យសុវត្ថិភាពប្រាំង, ពិនិត្យតំរង់ខ្យល់កាប៊ីន, ពិនិត្យនិងចាក់បំពេញប្រេងប្រាំង, តេសអាគុយ, ពិនិត្យប្រព័ន្ធក្នុងរថយន្ត។

**លោកអ្នកកាន់តែចំណាយ លោកអ្នកកាន់តែសន្សំ!**

$50 - $149 .................. Save $10
$150 - $249 .................Save $25
$250 រឺច្រើនជាងនេះ : ........Save $50

សូមមកជួបសម្រាប់ព័ត៌មានបន្ថែម។ ការលើកលែងអាចនឹងមាន។ ការផ្តល់ជូននេះមិនអាចបញ្ចូលគ្នាបានទេ។ ការផ្តល់ជូនកំណត់សម្រាប់តែមួយគ្រួសារ។ ត្រូវបង្ហាញខិតប័ណ្ណនេះក្នុងកំពុងពេលវេលាលក់។ ផុតកំណត់ថ្ងៃទី 4/30/19។

**សម្រាប់ព័ត៌មានបន្ថែមពីរថយន្ត**
សូមទំនាក់ទំនង ខេលី វីដាល: **kvidal@bochhondawest.com**

**ត្រូវការបុគ្គលិកផ្នែកលក់!**
ទំនាក់ទំនងមកកាន់ ខេរិន រេជ:kcregg@bochhondawest.com

**BochHondaWest.com | (978) 252-2125** HONDA




## ផ្ដើមសេចក្ដី

អារម្ភកថា

យើងសូមជូនរឿងថ្មីមួយទៀត គឺរឿង"កុមារ យោធិន្ទ"ជាប្រវត្តិកុមារប្រមាណជា១ពាន់នាក់ ដែលបានចូលទៅបំរើក្នុងកងទ័ពតាំងពីអាយុ១០ឆ្នាំ នៅសាលារៀនមួយដែលកងខេមរភូមិន្ទបាន បង្កើតឡើងបន្តពីអាណានិគមបារាំងក្នុងបំណងជួយចិញ្ចឹមកូនរបស់កងទ័ពបង្ហាត់បង្រៀនមុខវិជ្ជាដែល ឪពុករបស់គេស្រឡាញ់ចូលចិត្តនឹងបានបូជាជីវិត ដើម្បីមាតុភូមិរបស់គេថែមទៀត។

ជារឿងពិតរបស់យុវជនមួយក្រុមរស់នៅដាច់ពីការថ្នាក់ថ្នមរបស់ឪពុកម្ដាយមិនដូចក្មេង ឯទៀត គេចិញ្ចឹមកុមារទាំងនោះ ក្រោមវិន័យតឹងរឹងនៃកងទ័ពបង្ហាត់ហ្វឹកហ្វឺននឹងរៀនសូត្រវិជ្ជា ចម្បាំងតាំងតែពីនៅតូច តែសាធារណជនមិនសូវដែលដឹងថា"សាលានោះជាអ្វី?បង្ហាត់បង្រៀន របៀបណា? នឹងស្គាល់ថា ជាអ្វីនោះទេ" ក្រៅតែពីអ្នកនៅក្នុងក្រុងជាមួយនឹងអ្នកមិនឆ្ងាយពីបន្ទាយ នៃកូនទាហ៊ានទាំងនោះ តែប៉ុណ្ណោះដែលស្គាល់ ហើយឱ្យឈ្មោះថា"ពួកក្មេងហ្វង" ដែលជាឈ្មោះ បកប្រែពីពាក្យបារាំងមកថា"Les enfants de troupe"។

# ជីវភាពសិស្សសាលាកុមារយោធិន្ទ(ត)

### ភាគ១ - សាលាកងកុមារយោធិន្ទ

តពីលេខមុន

នាងច្រៀងថា...វាលវែងឆ្ងាយ!... សិស្សកុមារយោ ធិន្ទតែងនាំគ្នាបន្ទរថា "វ៉ែកឆា! វ៉ែកឆា!" ធ្វើឱ្យសែពកូស៊ីនខឹងសម្បារជាខ្លាំង ដោយ "វ៉ែក ឆា" បានក្លាយជាងាររបស់គាត់ ពីព្រោះ


ប្រជុំជួរ ដើម្បីគោរពទង់ជាតិរៀងរាល់ព្រឹក

តែហារខឹងសម្បាររបស់គាត់នោះ តែជាការរីករាយនឹងអរគុណរបស់សិស្សតាំងពីពេលនោះមក។

ក្នុងចំណោមម្ហូបអាហារដែលបំរើសិស្សរាល់ថ្ងៃ ដែលគេហៅថា"បាយប្លួ" នៅចងចាំជាងគេ គឺម្ហូបដែលផ្គុំគ្នា មានសម្លរម្ជូរឃ្លួន រួមនឹងសាច់គោឆាបន្ទះៗ -បបរសពងទាប្រៃ - ឆារ នោងសាច់ជ្រូក-នុំបុំងទឹកដោះគោខាប់ -ខ្លះក៏ចូលចិត្តបាយក្ដាំងលាបទឹកចំណុះខ្លាញ់លាយស្ករ ខ្ទឹម ដែលជាម្ហូបក្រៅស្ពកទៅវិញ... តែពុំដែលឮថាមានការពុលម្ហូបអាហាររួមម្ដងណានោះ ទេ។ សិស្សតូចៗ ពេលចូលរោងបាយមានអាកប្បកិរិយាច្រងេងច្រងាងបន្តិចមែន ពីព្រោះ តែឃ្លានតែពួកចាស់ៗ គេមានសណ្ដាប់ធ្នាប់ មានស្លាព្រាសម នឹងកន្សែងជូតមាត់... ឯក្មេងៗ គ្មានអ្វីទាំងអស់ ស៊ុបាយគោះចាន ពិតយកតែពីឈ្នះដៃបាយមិនដល់១០នាទីទេ ក៏ចប់ពិធីរួចជាស្រេចតែសិស្សធំគេនៅជុំគ្នាពេលហូបបាយជជែកគ្នាបានយូរបន្តិច... មានសិស្សខ្លះមកមិនទាន់ពេល ក៏ត្រូវគេលួចស៊ីចំណែករបស់ខ្លួនអស់ ក៏មានដើរជេផងរអ៊ូរផង ដូច្នេះការមកទាន់ពេលក៏សំខាន់ណាស់ដែរ ...សិស្សខ្លះដោយនៅហាត់ប្រាណក្នុងបន្ទាយនៅឡើយ ក៏ខំរត់មកដួសបាយនឹងម្ហូបចំណែកខ្លួនទុក នៅបន្តហាត់ដល់ចប់ ទើបហូបបាយ តែក៏មិនឱ្យឃ្លីតពេលពេកដែរ ពីព្រោះការចូលរៀនពេលយប់ "Salle d'etude"គឺនៅម៉ោង៧យប់ ក៏នឹងមកដល់មិនអាចឃឺតបានទេ។ តែក៏មានករណីលើកលែងខ្លះដែរ សម្រាប់សិស្សដែលទៅហាត់ហែលទឹកសម្រាប់ប្រកួតប្រណាំងនៅ"អាងទឹក-Piscine cercle sportif" នឹងសិស្សទៅហាត់ "យូដូ-Judo"គេទុកឱ្យសិស្សទាំងនោះរហុតដល់ម៉ោង៦ល្ងាចបាន។

នៅជុំវិញរោងអាហាររបស់សិស្សកុមារយោធានោះ មានរឿងជាច្រើនដែលបានកើតឡើងជុំវិញការធាត់ធំមិនដូចកុមារឯទៀត របស់សិស្សកុមារយោធា។ សិស្សធំខ្លះ តែងរំលោភដោយដាក់ទណ្ឌកម្មដល់សិស្សតូច ឬក៏ប្រើគ្នាឱ្យធ្វើអ្វីមួយឱ្យ ដែលជាកាងារមិនចាំបាច់ចាប់ម្ហូបពេលល្ងាចទុកឱ្យជាប្រចាំឱ្យខ្លួនអាចធ្វើអ្វីផ្សេងបានរត់ទៅទិញគ្រឿងក្រៅផ្សំម្ហូប នារសៀលថ្ងៃអាទិត្យ បន្ទាប់ពីចាប់ត្រី ឬចាប់ក្ដាម ឬចាប់ចង្រិតបានយកមកហូប...។ល។ ក្មេងៗតែងតែធ្វើឱ្យជានិច្ចកុំឱ្យតែខោកក្បាលគ្នាជាការស្រេចឱ្យធ្វើអីក៏ធ្វើដែរ។

បង សុខ បង អុន ឬបងង៉ូវ ច្រើនរហ័សដៃណាស់ អារឿងខោកក្បាលនោះ ជូនកាលក្មេងៗមិនចាំខោកក្បាលវាទេ គឺឱ្យពួកវារត់មកជល់នឹង"ក្រញ៉"ពួកគាត់ទៅវិញ កុំឱ្យគាត់ហត់នឹងប្រឹងខោក។ ទ្រង់ស៊ីសុវត្ថិប៉ុណ្ណារក្សអត្តលេខ៧៥៦ ជាសិស្សចូលថ្មីបានត្រូវបងសុខសិស្សធំអត្តលេខ១៥៧ វាយទាត់ធាក់ធ្វើឱ្យរបួសយ៉ាងដំណំ ដោយសារមិនស្ដាប់បង្គាប់... រឿងនេះបានធ្វើឱ្យល្បីយ៉ាងឆ្ងាយដល់រាជវង្សទៀតផង។

ជាអកុសលសាលាកងកុមារយោធិន្ទមិនបានបើកទ្វារជារហូតតទៅទេ ឆ្នាំ១៩៧០ សង្គ្រាម ក៏មកដល់ដោយសារតែកម្ពុជាបានប្ដូររបបជាសាធារណរដ្ឋ ឯ"សាលាកងកុមាយោធិន្ទ"ក៏ប្ដូរឈ្មោះទៅជា"សាលាកងកុមាយោធា" តែមិនបានប្ដូរឈ្មោះបារាំងពី"ETK-Ecole des enfants de troupe Khmer"នោះទេ។ ឆ្នាំ១៩៧៣សាលាកងកុមារយោធានៅកំពង់ចាម ក៏បានបិទទ្វារ ជាមួយនឹងមេបញ្ជាចុងក្រោយបង្អស់ឈ្មោះ លោក ទឹម ថូ រីឯកុមារយោធិន្ទគង់ សម្បត្តិ អត្តលេខ១០៧៧ គឺជាកុមាយោធាចុងក្រោយគេបង្អស់, សិស្សម្នាក់ដែលមានអត្តលេខគួរឱ្យចងចាំដែរ គឺសិស្សកុមារយោធាបូកែវ គិមហាន អត្តលេខ១០០០។ គេនៅចងចាំសិស្សកុមាយោធិន្ទ ជារៀមច្បងដំបូងគេមានអត្តលេខ១ ក្រោយមកបានក្លាយជាឧត្តមសេ នីយ ខ្លូត ប៊ុត នៃកងខេមរភូមិន្ទព្រះរាជាណាចក្រកម្ពុជា ។

(នៅមានតទៅលេខក្រោយ)

LOWELL

សមាគមបាល់ទាត់ យុវជននៅឡូវែល

Lowell Youth Soccer Association

Spring Registration — ចុះឈ្មោះសម្រាប់រដូវផ្ការីក
Teams are available for — នៅសល់កន្លែងទំនេរ

Ages 3-11 Recreation League — អាយុ ៣-១១ឆ្នាំ ក្រុមហាត់ទាត់បាល់

9-14 Travel League - — អាយុ ៩-១៤ ឆ្នាំ ចាប់ផ្ដើមប្រកួត

* Limited positions are available - Boys and Girls Under-10 - - Under-14
កំណត់កន្លែងដែលនៅសល់ -ក្មេងស្រី និងក្មេងប្រុសអាយុតិចជាង១០ឆ្នាំ -អាយុតិចជាង១៤ឆ្នាំ



Register On-line at:
lowellsoccer.com




# ការបើកសម្ភោធឡើងវិញនៅថ្ងៃទី ១ ខែមិនា ខាងមុខនេះ

សូមមកធ្វើការណាត់ជួបជាមុននៅពេលឥឡូវនេះ

ហើយទទួលបានឧបករណ៍ធ្វើឲ្យធ្មេញសដោយមិនគិតថ្លៃ

យើងនិយាយភាសាខ្មែរ

ទទួលយកធានារ៉ាប់រងពីក្រុមហ៊ុនធំ និងរដ្ឋ

## ពេទ្យធ្មេញ

**Dracut Family Dental**
14 Loon Hill Road • Dracut, MA 01826
978-955-9005
dracutdental@gmail.com

DRACUT FAMILY DENTAL

TOP DENTISTS 2018 AWARDED BY BOSTON MAGAZINE



## We make health care easy

Neighborhood has affordable plans for:

- Children and families
- Individuals
- Small businesses

## យើងធ្វើឲ្យការថែទាំសុខភាពងាយស្រួល

Neighborhood មាន គម្រោងដែលមានតម្លៃសមរម្យសម្រាប់៖

- កុមារ និងក្រុមគ្រួសារ
- បុគ្គលម្នាក់ៗ
- អាជីវកម្មខ្នាតតូច

Neighborhood Health Plan OF RHODE ISLAND™

Contact us today to learn more!
សូមទាក់ទងមកយើងខ្ញុំនៅថ្ងៃនេះ
ដើម្បីស្វែងយល់បន្ថែម!
www.nhpri.org



## KhmerPost USA, LLC
## សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក





**អគ្គនាយក សុបិន្ទ ពិន**
Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
sobenpin@khmerpost.us





**និពន្ធនាយកខ្មែរ** Khmer Editorial
និពន្ធនាយក ពិន សំខុន
Roger Samkhon Pin, Co-founder|Editor
(978-942-1641| rogerpin@khmerpost.us





Richard Howe Jr.
Contributed Writer | Editor

**ផ្សាយពាណិជ្ជកម្ម សុបិន្ទ ពិន**
Advertising Contact
Soben Pin
Cell: 979-656-8141
sobenpin@khmerpost.us

**អ្នកនិពន្ធកិត្តិយស** Staff Writer| Translator
Sokharath Koy

**ច្នៃសោភ័ណ្ឌភាព** Design Artist
Heng Chhun Leng



The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.
Follow us: Facebook | Twitter KhmerpostUSA

តមកពីទំព័រទី ០៣

## ការផ្លាស់ប្តូរឈ្មោះឧទ្យាននៅផ្លូវប្រែញ

ប្រាស់ឧទ្យាននេះទៀតហើយ។ ជាងនេះទៅទៀត ក្រុមលេងបាល់បោះតូចរបស់សហគមន៍អាមេរិកឡាទីន មានទូវទីលានារបស់ខ្លួនផ្ទាល់ដែលមានឈ្មោះថា រ៉ូប៉េតូ ក្លេម៉ិនតេ ខាងក្រោយសាលារៀន បាលេត ម៉ិឌុលស្កូលកាលពី២ឆ្នាំមុន ដែលរូបលោកមានមោទនភាពក្នុងការធ្វើការងារជាមួយនឹងសាលាក្រុងដើម្បីសម្រេចចេញជាឈ្មោះនេះសម្រាប់សហគមន៍អា-មេរិកឡាទីន។ លោក អ៊ីល្បៀត លើកឡើងថា "ម្នាក់ៗមកវកយើងវិញ ដែលសហគមន៍អាមេរិកឡាទីន និងអាស៊ីភាគខាងត្បូងរស់នៅមិនចុះសម្រុងនិងគ្នា។ នេះមិនមែនជាអ្វីដែលយើងសមនិងទទួល និងអ្វីដែលយើងត្រូវការនោះទេ។ លោក សុវណ្ណា ក៏បាន បញ្ជាក់ថា សហគមន៏ខ្មែរ និងអាមេរិកឡាទីនមួយចំនួន មិនបានជ្រុលជ្រាបឱ្យបានពេញលេញពីដំណើរការនៃផ្លាស់ប្តូរឈ្មោះនេះនោះទេ ហើយវានឹងបង្កើតឱ្យមានការយល់ច្រលំមួយចំនួន។ អាស្រ័យហេតុនេះ លោក




មានការរីករាយ។ នេះគឺអ្វីដែលខ្ញុំបានឃើញ"។

ចំណែកលោក ពៅ សុវណ្ណា ប្រធានសមាគមន៏ខ្មែរប្រចាំទីក្រុងឡូវែលបានលើកឡើងតាមរយៈគណនីហ្វេសបុកផ្ទាល់ខ្លួនរបស់លោកថា កិច្ចខិតខំប្រឹងប្រែងផ្លាស់ប្តូរឈ្មោះវានឹងប៉ះពាល់ខ្លាំងដល់អ្នកមួយចំនួននៅពេលដែលយើងចាប់ផ្តើមគិតអំពីហេតុផលនៃការមិនទុកចិត្តគ្នា។ វានឹងអាចធ្វើឱ្យការចងចាំដ៏ខ្មៅងងឹតមួយចំនួននៅដើមទសវត្សទី៩០ វិលត្រឡប់មកវកយើងវិញ ... សុវណ្ណា ស្នើរឱ្យមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សហគមន៏របស់យើងតាមការដែលអាចធ្វើទៅបានដើម្បីឱ្យពួកគេអាចទទួលបានព័ត៌មាន និងចូលរួមនៅពេលធ្វើការដោះស្រាយបញ្ហាណាមួយឱ្យឈានទៅមុខ។លោកបានបញ្ជាក់ថានេះជាឱកាសដ៏ធំមួយសម្រាប់យើងទាំងអស់គ្នា ដើម្បីធ្វើការរួមគ្នាក្នុងគោលបំណងដើម្បីឈានសម្រេចបាននូវដំណោះស្រាយរួមមួយ។

# បុណ្យចូលឆ្នាំថ្មី

## សួស្តីឆ្នាំថ្មី ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ខ្ញុំព្រះករុណាអាត្មាភាព យើងខ្ញុំជាគណកម្មការ អាចារ្យ និងពុទ្ធបរិស័ទ ចំណុះជើងវត្ត **មណ្ឌលពុទ្ធសាសនា** បានមូលមតិគ្នាប្រារព្ធពិធីចូលឆ្នាំថ្មីតាមប្រពៃរបស់ជាតិខ្មែរយើង និងទៅតាមមហាសង្ក្រាន្តខ្មែរ ។ នៅក្នុងឆ្នាំថ្មីនេះ មានទេវតា ព្រះនាម**ទុង្សៈសក់ខេចទី** ជាបុត្រីទី១នៃកបិលព្រះមហាព្រហ្ម យាង ចុះមក ថែរក្សាមនុស្សលោកក្នុងចក្រវាឡយើងនេះ នៅថ្ងៃសៅរ៍ ទី១៤ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង ០៣:១២នាទី ។

សូមអញ្ជើញអស់លោកស្រី និងពុទ្ធបរិស័ទគ្រប់ចតុទិសទី មេត្តាអញ្ជើញចូលរួមកម្មវិធីចូលឆ្នាំកុរឱ្យបានកុះករ ។

### កម្មវិធីបុណ្យ

-ថ្ងៃសុក្រ ទី១២ ខែមេសា : ម៉ោង៦:៣០នាទី : និមន្តព្រះសង្ឃសំដែងព្រះបរិត្ត និងសំដែងធម៌ទេសនា
-ថ្ងៃសៅរ៍ ទី១៣ ខែមេសា : ម៉ោង៩:៣០នាទី : រាប់បាត ដារបង្សុកូល
-ម៉ោង១១:១០នាទីព្រឹក : វេរភត្តប្រគេនព្រះសង្ឃ និងនិមន្តព្រះគ្រូ យៀង សុចិត្រា សំដែងធម៌ទេសនា
-ម៉ោង១២:០០នាទី : អញ្ជើញភ្ញៀវ និងពុទ្ធបរិស័ទទទួលភោជនាហារ ។
-ម៉ោង១២:១៥នាទី : ពិធីផ្ទេរវេនទេវតាឆ្នាំថ្មី និងរបាំជូនពរ រហូតដល់ម៉ោង៦:០០ល្ងាច
-ម៉ោង០៦:៣០នាទីល្ងាច : និមន្តព្រះសង្ឃសំដែងព្រះបរិត្ត និងមន្តព្រះតេជគុណ យឹម យ៉ុន សំដែងធម៌

**ថ្ងៃអាទិត្យ ទី១៤ ខែមេសា ឆ្នាំ២០១៩**

-ម៉ោង០៩:០០នាទីព្រឹក : ជួបជុំពុទ្ធបរិស័ទមានភ្លេងបុរាណ និងក្រុមឆៃយ៉ាំលេងប្រគុំកំដរកំសាន្ត រាប់បាទដារបង្សុកូល និងប្រគេនចង្ហាន់
-ម៉ោង១១:១៥នាទីព្រឹក : និមន្តលោកម្ចាស់ លីនសុមនោរម្យញាណ សំដែងធម៌ទេសនា
-ម៉ោង១២:១០-៦:០០នាទីព្រឹក : មានរបាំត្រុដិ និងតន្ត្រីបុរាណ ប្រគុំច្រៀង
-ម៉ោង០១:០០ល្ងាច : ស្រង់ទឹកព្រះ ស្រង់ទឹកព្រះសង្ឃ និងធ្វើកិច្ចពុទ្ធាភិសេក ។

**ថ្ងៃអង្គារ ទី១៥_១៦ ខែមេសា ឆ្នាំ២០១៩**

ជាថ្ងៃវារៈវ័នបត និងថ្ងៃវារៈឡើងស័កតាមប្រតិទិនកម្មវិធីបុណ្យចូលឆ្នាំខ្មែរ
ថ្ងៃច័ន្ទ អង្គារ មានបង្សុកូល និងប្រគេនចង្ហាន់ព្រះសង្ឃជាដើម ។

**ថ្ងៃសៅរ៍ អាទិត្យ ទី២០ និង២១ ជាថ្ងៃឆ្លងបុណ្យចូលឆ្នាំថ្មី ប្រចាំវត្ត**
**សូមបញ្ជាក់: ជារៀងរាល់ថ្ងៃមានលេងល្បែងប្រជាប្រិយ៍ និងពូនភ្នំខ្សាច់**






**មណ្ឌលពិនិត្យសុខភាពលីន**

**Lynn Primary Care Center**

**លោកវេជ្ជបណ្ឌិត មី សុខារិទ្ធ, M.D.**

**Sokharith Mey, M.D.**

ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

Now Accepting New Patients

អាស័យដ្ឋាន

280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755

ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត

បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

LYNN PRIMARY CARE CENTER
មណ្ឌលពិនិត្យសុខភាពលីន

ជំងឺទូទៅ

*Family Medicine*

សុខភាពផ្លូវចិត្ត

*Behavioral Health*

We Accept MassHealth, Medicare and Other Health Insurances

Our Staff Speaks Khmer

# A Great Night Out Either Begins Or Ends at Heritage Farm.




- Mondays: Classic Car Show & Free Concert Series
- Tuesdays: Bike Nite for Jimmy Fund
- Thursdays: Kids Night

*All Starting at 6:00 PM*
*All Summer Long*

HERITAGE FARM
ICE CREAM & RESTAURANT

163 Pawtucket Blvd.
Lowell, Mass.
(978) 459-0802
HeritageFarmIceCream.com

**DEPUTY SHERIFF**

The Rhode Island Department of Public Safety, Division of Sheriffs, is now recruiting qualified, motivated individuals who are seeking full-time employment as a Deputy Sheriff.

DEPUTY SHERIFFS perform courtroom security, inmate and prisoner transportation, extraditions and the execution of court documents.

Applications are being accepted through: **April 28, 2019**

For more information visit: WWW.SHERIFFS.RI.GOV

The State of Rhode Island, Department of Public Safety, is an Equal Opportunity and Diversity Employer.

To Apply Visit www.apply.ri.gov

# Explore Spring in the Greater Merrimack Valley

Just a half-hour drive northwest of Boston lies the Greater Merrimack Valley. The changing seasons add to the vibrancy of the region.

There is an undeniable spirit in the Greater Merrimack Valley – the same spirit that gave birth to our country. Each of our 21 towns and cities has its own unique charm and itinerary you need.


















**Your next adventure awaits you here!**

Greater Merrimack Valley
Convention & Visitors Bureau
adventuresawait
merrimackvalley.org

MASSACHUSETTS
massvacation.com

**merrimackvalley.org**

Follow us on Twitter and Instagram @MerrimackValley

# RI State Police to Increase Enforcement of Texting/Hand-held

# Cell Phone Laws During 'U Text. U Drive. U Pay.' Campaign

Colonel James M. Manni, Superintendent of the Rhode Island State Police and Director of the Rhode Island Department of Public Safety, announces that additional troopers have been assigned to special patrols next week to enforce the state's texting-while-driving and hands-free cell phone use laws as part a national highway safety campaign called U Drive. U Text. U Pay.

"Distracted driving has become a major cause of death and injury on our roadways, in large part because of hand-held cell phone use while driving," Colonel Manni said. "We hope this enforcement campaign will remind motorists to put down their phones while they drive."




At any given moment, about 660,000 drivers nationwide are using their cell phones or manipulating electronic devices, according to a study by the National Highway Traffic Safety Administration. This has become a leading cause of death and injury in motor vehicle crashes nationwide.

The National Safety Council estimates that at least nine people die and 100 are injured each day in crashes caused by distracted driving. "Cell phones, dashboard touchscreens, voice commands and other in-vehicle technologies pose a threat to our safety," the NSC reports.

That's why NHTSA has declared April as Distracted Driving Awareness Month and provided funding for extra enforcement during the U Drive. U Text. U Pay. campaign from April 7 through 13.

Texting while driving is of particular concern, according to NHTSA, because the average person takes his or her eyes off the road for five seconds to read or send a text. When driving 55 miles an hour, that's the equivalent of driving the entire length of a football field with your eyes closed.

"Taking your eyes off the road for even a split second greatly increases the risk of getting involved in a crash," Colonel Manni said. "Our goal is to remind everyone to put down their phones, avoid distractions and drive safely."

Rhode Island laws prohibit texting while driving as well as the use of hand-held cell phones and other communication devices while driving. Anyone found talking or texting on a hand-held device faces fines up to $100 and/or a license suspension up to 30 days. Article is submitted by Rhode Island Department of Public Safety; Laura Meade Kirk.

KhmerPost USA

The **KhmerPost USA** is the premier **free** biweekly newspaper for Khmer and English readers. We committed to the best news and information to our readers and advertisers that we have provided for the past 10 years to the Cambodian communities in New England.

Currently reaching 50,000 readers every month
Distribution outlets include:

- Local Markets and Convenience Stores
- Restaurants, Retail Stores, and Chambers of Commerce
- Government Offices and Office Buildings
- Cleaners and Laundromats
- Buddhist Temples and much more

**For Advertising Opportunities**
**Contact:** 978.677.7163
Web: www.khmerpostusa.com

Celebrating 10 Years of Service

**REACH THOUSANDS OF PEOPLE IN THE CAMBODIAN COMMUNITY WITH**
**COST EFFECTIVE NEWSPAPER ADVERTISING**




**PUBLISHING**
Two Issues Every Month

**READERSHIP**
50,000 Monthly
600,000 Annually

*Khmer Post USA Distribution Locations:*

- Households
- Markets
- Retail Businesses
- Restaurants
- Office Buildings
- Government Offices
- Chamber of Commerce
- Buddhist Temples
- Laundromats
- And Much More

| | |
|---|---|
| 7Jan and 21 | 8 July and 22 |
| 4 Feb and 18 | 5 Aug and 19 |
| 4 March and 18 | 9 Sept and 23 |
| 8 April and 22 | 7 Oct and 21 |
| 6 May and 20 | 9 Nov and 23 |
| 10 Jun and 24 | 6 Dec and 20 |

Advertising deadlines are 5 business days prior to printing date.

KhmerPost USA is a free Cambodian-English biweekly newspaper serving Lowell, Chelmsford, Tyngsboro, Lynn and Revere, MA as well as Cranston and Providence, RI.

It was founded in 2007 by Soben Pin and partner Roger Pin. In 2010, they relocated the newspaper to Lowell to meet the demand for readership.

With an annual readership of 600,000, it is the only premier voice for the Cambodian-American community across the New England region.

Web: www.khmerpostusa.com


MAYURA
ផ្ញើឥវ៉ាន់ទៅស្រុកខ្មែរ
SEND STUFFS TO CAMBODIA
Send to Khmer
FRAGILE
handle with care
Tel: 978- 998-0707
978- 876-1985
21 Branch Street. Unit 2 | Lowell, MA 01851